សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# អាជ្ញាយុកាលនៃការរំលត់សិទ្ធិ លើបំណុលក្នុងកិច្ចសន្យា

ស្រាវជ្រាវថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១៦ ដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ ២០១៦

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **ហាង់ ភ័ក្រ្តា**
**ហេង ដារ៉ា**

សាស្ត្រាចារ្យណែនាំ
លោក **ឌិន វណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៦

ឆ្នាំចូលរៀន ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ ហាង់ ភ័ក្រ្តា និងហេង ដារ៉ា ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាបឋមយើងខ្ញុំទាំងពីរសូមលំឱនកាយគោរព សំដែងនូវកតញ្ញូតាធម៌ និងសេចក្តីដឹងគុណជូនចំពោះលោកឪពុក និងអ្នកម្តាយរបស់យើងខ្ញុំបាទទាំងពីរ ដែលលោកទាំងពីរបានបង្កើត ចិញ្ចឹមផ្គត់ផ្គង់ ផ្តល់កម្លាំងចិត្ត និងសុភមង្គលដល់រូបយើងខ្ញុំទាំងពីរ ធ្វើឱ្យខ្ញុំបាទទាំងពីររស់នៅក្នុងជីវិតដ៏សុខស្រួល និងអាចរៀនបានខ្ពង់ខ្ពស់ដូចសព្វថ្ងៃនេះ។

បន្ទាប់មកយើងខ្ញុំទាំងពីរ ក៏សូមសំដែងនូវសេចក្តីដឹងគុណជាពិសេសផងដែរ ជូនចំពោះ៖

- ឯកឧត្តម បណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការនៃសាកលនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- លោកសាស្ត្រាចារ្យ ជិន វណ្ណារ៉ា ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ពន្យល់ និងផ្តល់ជាវិធីសាស្ត្រល្អៗ ក្នុងដំណើរការនៃការរៀបរៀងអត្ថបទសារណានេះតាំងពីដើមរហូតដល់ចប់។
- លោក សាស្ត្រាចារ្យ និងលោកស្រី សាស្ត្រាចារ្យទាំងអស់ នៅក្នុងមហាវិទ្យាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យសាស្ត្រសេដ្ឋកិច្ច ដែលលោកទាំងអស់បានខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់ក្នុងការផ្តល់ចំណេះដឹង និងបទពិសោធន៍ល្អដល់រូបយើងខ្ញុំទាំងពីរ ក្នុងអំឡុងពេល ៤ ឆ្នាំកន្លងមក។
- មិត្តភ័ក្តិទាំងអស់ដែលបានណែនាំ និងផ្តល់ជាមតិយោបល់ល្អៗ ក្នុងការរៀបរៀងសារណានេះ។

ជាចុងក្រោយ យើងខ្ញុំទាំងពីរសូមគោរពជូនពរដល់លោកឪពុក អ្នកម្តាយ បងប្អូនប្រុសស្រី លោកគ្រូ អ្នកគ្រូ និងមិត្តភ័ក្តិដែលបានជួយជ្រោមជ្រែងខ្ញុំបាទទាំងពីរ ឱ្យបញ្ចប់ការរៀបរៀងសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនេះប្រកបដោយភាពជោគជ័យ ឱ្យជួបប្រទះតែពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណ: សុខ: ពល: ជានិច្ចនិរន្តន៍ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាប័ត្រផ្នែកនីតិសាស្ត្រ អស់អំឡុងពេលបួនឆ្នាំរួចមក យើងខ្ញុំបានទទួលនូវចំណេះដឹងយ៉ាងច្រើន រួមជាមួយនិងការសិក្សាស្រាវជ្រាវពីស្ថានភាពជាក់ស្តែងនៃសង្គមផងដែរ ។ ក្នុងចំណោមមុខវិជ្ជាដែលបានសិក្សា យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើវិស័យរដ្ឋប្បវេណីដែលធ្វើឱ្យខ្ញុំបាទទាំងពីរសម្រេចជ្រើសយកប្រធានបទស្តីពី **អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្នុងកិច្ចសន្យា** មកចងក្រងជាសារណាសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្ររបស់យើងខ្ញុំ ។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្នុងកិច្ចសន្យា គឺជាអំឡុងពេលដែលកំណត់ដោយច្បាប់ដែលផ្តល់សិទ្ធិឱ្យម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបាន ។ ប្រសិនបើម្ចាស់បំណុលមិនអនុវត្តសិទ្ធិរបស់ខ្លួនក្នុងអំឡុងពេល ៥ឆ្នាំគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិបានទេ ម្ចាស់បំណុលនឹងរលត់សិទ្ធិរបស់ខ្លួន ។ ប៉ុន្តែទោះបីជាហួសអំឡុងពេល ៥ឆ្នាំក៏ដោយ ឱ្យតែកូនបំណុលមិនលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ ហើយទទួលស្គាល់សិទ្ធិលើបំណុលនោះ ម្ចាស់បំណុលនៅតែមានសិទ្ធិលើបំណុលដដែល ។ នៅក្នុងការចងក្រងសារណានេះយើងខ្ញុំបានពឹងផ្អែកលើ ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ និងក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ព្រមទាំងបទដ្ឋានគតិយុត្តិនានាដែលពាក់ព័ន្ធ ។

ជាថ្មីម្តងទៀត យើងខ្ញុំសង្ឃឹមថាសារណានេះនឹងអាចជួយរួមចំណែកក្នុងការសិក្សាស្រាវជ្រាវសម្រាប់និស្សិតជំនាន់ក្រោយៗ និងក្នុងការអនុវត្តពាក់ព័ន្ធនឹងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្នុងកិច្ចសន្យា នៅក្នុងសង្គមជាក់ស្តែង ។ ដោយពេលវេលានៃការស្រាវជ្រាវមានកម្រិត គួបផ្សំចំណេះដឹងជាមូលដ្ឋាន និងការខិតខំស្រាវជ្រាវពិចារណាហើយ និងការរៀបចំចងក្រងរបស់យើងខ្ញុំនៅមានកម្រិតនោះ គឺវាពិតជានាំឱ្យលេចចេញនូវភាពខ្វះខាតជាក់ជាពុំខាន ។ យើងខ្ញុំរីករាយនឹងទទួលនូវការរិះគន់ពីសំណាក់សាស្ត្រាចារ្យ រៀមច្បង និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ដើម្បីឱ្យស្នាដៃនេះកាន់តែមានភាពប្រសើរឡើង ។

ជាចុងបញ្ចប់ យើងខ្ញុំសូមបួងសួងឱ្យអស់លោក លោកស្រី មិត្តសិស្សិ និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ប្រកបដោយសុខភាពល្អបរិបូរណ៍ និងទទួលបានជោគជ័យនៅក្នុងការងារ និងការសិក្សាជានិរន្តន៍។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** .......... ១

## ជំពូកទី ១
## សញ្ញាណទូទៅនៃអាជ្ញាយុកាល និងសិទ្ធិលើបំណុល

**១.១. អាជ្ញាយុកាល** .......... ៤
**១.១.១. អាជ្ញាយុកាលនៃលទ្ធកម្ម** .......... ៤
១.១.១.១. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិ .......... ៤
១.១.១.១.១. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ .......... ៤
ក. គោលគំនិត .......... ៤
ខ. និយមន័យ .......... ៥
គ. លក្ខខណ្ឌអាជ្ញាយុកាលលទ្ធកម្មកម្មសិទ្ធិ .......... ៥
១.១.១.១.២. អាជ្ញាយុកាលលទ្ធកម្មសិទ្ធិលើចលនវត្ថុ .......... ៦
១.១.១.២. អាជ្ញាយុកាលលទ្ធកម្មសិទ្ធិ .......... ៧
១.១.១.២.១. អាជ្ញាយុកាលលទ្ធកម្មសិទ្ធិទាក់ទងនឹងអចលនវត្ថុ .......... ៧
១.១.១.២.២. អាជ្ញាយុកាលលទ្ធកម្មសិទ្ធិទាក់ទងនឹងចលនវត្ថុ .......... ៧
**១.១.២. អាជ្ញាយុកាលនៃការរំលត់សិទ្ធិ** .......... ៨
១.១.២.១. និយមន័យ .......... ៨
១.១.២.២ ប្រភេទអាជ្ញាយុកាលរំលត់សិទ្ធិ .......... ៨
១.១.២.២.១. អាជ្ញាយុកាលរំលត់សិទ្ធិក្នុងកិច្ចសន្យា .......... ៨
១.១.២.២.២. អាជ្ញាយុកាលរំលត់សិទ្ធិក្រៅកិច្ចសន្យា .......... ៩
**១.២. សិទ្ធិលើបំណុល** .......... ៩
**១.២.១. ប្រវត្តិនៃសិទ្ធិលើបំណុល** .......... ៩
១.២.១.១. ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ បកប្រែដោយលោក អេង សុត ឆ្នាំ ១៩៦៧ .......... ៩
១.២.១.២. ក្រឹត្យច្បាប់លេខ ៣៨ .......... ១០
១.២.១.៣. ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ .......... ១០

**១.២.២. ប្រភេទសិទ្ធិលើបំណុល** ..... ១១
១.២.២.១. កិច្ចសន្យា ..... ១១
១.២.២.២. សកម្មភាពឯកតោភាគី ..... ១១
១.២.២.៣. ការគ្រប់គ្រងដោយឈឺឆ្អាល ..... ១២
១.២.២.៤. សេចក្តីចំរើនឥតហេតុ ..... ១២
១.២.២.៥. បញ្ញាត្តិច្បាប់ ..... ១២
**១.២.៣. ទំនាក់ទំនងសិទ្ធិលើបំណុល និងភាតព្វកិច្ច** ..... ១២

## ជំពូកទី ២
## យន្តការគតិយុត្តិនៃអាជ្ញាយុកាលលើការរំលត់សិទ្ធិលើបំណុល

**២.១. សញ្ញាណទូទៅនៃអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល** ..... ១៤
**២.១.១. គោលគំនិត** ..... ១៤
២.១.១.១. ស្ថេរភាព និងការថែរក្សានូវសណ្តាប់ធ្នាប់សង្គម ..... ១៤
២.១.១.២. បន្ថយនូវបញ្ហាលំបាកនៃការប្រមូលភស្តុតាង ..... ១៥
២.១.១.៣. ដាស់តឿនចំពោះជនដែលលង់លក់នឹងសិទ្ធិ ..... ១៥
**២.១.២. និយមន័យ** ..... ១៦
២.១.២.១. អាជ្ញាយុកាល ..... ១៦
២.១.២.២.សិទ្ធិលើបំណុល ..... ១៦
**២.១.៣. ជនពាក់ព័ន្ធ** ..... ១៧
២.១.៣.១. ម្ចាស់បំណុល ..... ១៧
២.១.៣.២. កូនបំណុល ឬកូនបំណុលដោយសាមគ្គី ..... ១៧
២.១.៣.៣. អ្នកធានា ..... ១៨
២.១.៣.៤. អ្នកធានាដោយវត្ថុ ..... ១៨
២.១.៣.៥. តតិយជនដែលបានធ្វើលទ្ធកម្ម ..... ១៨
២.១.៣.៦. សន្តតិជន ..... ១៩

**២.១.៤ វិសាលភាពនៃការលើកឡើង និងការបោះបង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល** ..... ១៩
២.១.៤.១. វិសាលភាពនៃការលើកឡើង ..... ១៩
២.១.៤.១.១. គោលការណ៍ចៅក្រមអកម្ម ..... ១៩
២១.៤.១.២. វិសាលនៃការលើកឡើងនូវអាជ្ញាយុកាលដោយកូនបំណុល ..... ២០
២.១.៤.១.៣. វិសាលភាពនៃការលើកឡើងអាជ្ញាយុកាលដោយជនក្រៅពីកូនបំណុល ..... ២១
២.១.៤.២. វិសាលភាពនៃការបោះបង់ផលប្រយោជន៍នៃអាជ្ញាយុកាល ..... ២២
២.១.៤.២.១. ការបោះបង់ផលប្រយោជន៍នៃអាជ្ញាយុកាលដោយកូនបំណុល ..... ២២
២.១.៤.២.២. ការបោះបង់ផលប្រយោជន៍នៃអាជ្ញាយុកាលដោយជនក្រៅពីកូនបំណុល ..... ២៣
**២.១.៥. ប្រភេទនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល** ..... ២៤
២.១.៥.១. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ ..... ២៤
២.១.៥.២. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមានអំឡុងពេលខ្លី ..... ២៥
២.១.៥.៣. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ ..... ២៦
**២.២ ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល** ..... ២៦
**២.២.១. លក្ខខណ្ឌ** ..... ២៦
២.២.១.១. អំឡុងពេលអាជ្ញាយុកាល ..... ២៦
២.២.១.១.១. ពេលចាប់ផ្ដើម ..... ២៦
ក. កិច្ចសន្យាដែលមានពេលកំណត់ជាក់លាក់ ..... ២៧
ខ. កិច្ចសន្យាដែលមានពេលកំណត់មិនពិតប្រាកដ ..... ២៧
គ. កិច្ចសន្យាដែលមានលក្ខខណ្ឌបង្អង់ ..... ២៨
២.២.១.១.២. អំឡុងពេល ..... ២៨
២.២.១.២. ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ..... ២៩
២.២.១.២.១. ភាពចាំបាច់នៃការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើ បំណុល ..... ២៩
២.២.១.២.២. បុគ្គលដែលអាចលើកឡើងនូវអាជ្ញាយុកាល ..... ២៩
**២.២.២. អានុភាពប្រតិសកម្ម** ..... ៣០

**២.៣. ករណីនៃការផ្អាក និងការបង្អង់អាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល** ............ ៣០
**២.៣.១. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល** ............ ៣១
២.៣.១.១. និយមន័យ ............ ៣១
២.៣.១.២. មូលហេតុដែលនាំឱ្យផ្អាកអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល ............ ៣១
២.៣.១.២.១. ការទាមទារតាមផ្លូវតុលាការ ............ ៣១
២.៣.១.២.២. ការចូលរួមក្នុងនីតិវិធីក្ស័យធន ............ ៣២
២.៣.១.២.៣. សកម្មភាពអនុវត្តដោយបង្ខំ ............ ៣២
២.៣.១.២.៤. សកម្មភាពចាត់ចែងរក្សាការពារ ............ ៣៣
២.៣.១.២.៥. ការទទួលស្គាល់កាតព្វកិច្ច ............ ៣៥
ក. ការសងមួយផ្នែក ............ ៣៥
ខ. ការបង់ការប្រាក់ ............ ៣៦
គ. ការដាក់ប្រាតិភោគ ............ ៣៦
២.៣.១.៣. អានុភាព ............ ៣៦
**២.៣.២. ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល** ............ ៣៧
២.៣.២.១. និយមន័យ ............ ៣៧
២.៣.២.២. មូលហេតុនៃការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ............ ៣៧
២.៣.២.២.១. ការលើកពាក្យបណ្ដឹង ............ ៣៨
២.៣.២.២.២. អនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ ............ ៣៨
២.៣.២.២.៣. សិទ្ធិលើបំណុលប្ដីប្រពន្ធ ............ ៣៨
២.៣.២.២.៤. មហន្តរាយ ............ ៣៩
២.៣.២.២.៥. ការដាស់តឿន ............ ៣៩
២.៣.២.៣. អានុភាពនៃការបង្អង់ ............ ៤០
**២.៣.៣. មូលហេតុដែលគ្មានអានុភាពនាំឱ្យផ្អាក ឬបង្អង់** ............ ៤១
២.៣.៣.១. ការលើកចោលពាក្យបណ្ដឹង ឬដកពាក្យបណ្ដឹងមុនការបញ្ជូនទៅចុងចម្លើយ ............ ៤១
២.៣.៣.២. ការលើកចោលការអនុវត្តដោយបង្ខំ ............ ៤១
២.៣.៣.៣. ការលើកចោលការចាត់ចែងរក្សាការពារ ............ ៤២

**សន្និដ្ឋាន**......................................................................................................................................៤៤
**អនុសាសន៍**......................................................................................................................................៤៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ដើម្បីរៀបចំឱ្យប្រទេសជាតិកាន់តែមានសន្តិភាពពេញលេញ រដ្ឋត្រូវកសាងច្បាប់ថ្មីៗ ឱ្យស្របតាមស្ថានភាពសង្គម តួយ៉ាងច្បាប់ដែលជាមូលដ្ឋានដើម្បីកសាងនីតិរដ្ឋនោះគឺ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី ២១ កញ្ញា ឆ្នាំ ១៩៩៣ និងត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ម្យ៉ាងវិញទៀតនៅពេលដែលប្រទេសជាតិកាន់តែរីកចម្រើន មានសន្តិភាពពេញលេញបរិបូរណ៍ ប្រជាជនតែងតែមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ហើយទំនាក់ទំនងនេះ តែងតែបង្កើតឱ្យមានចំណងគតិយុត្តិដែលបង្កើតឱ្យមានសិទ្ធិ និងកាតព្វកិច្ច ជាពិសេសគឺសិទ្ធិលើបំណុល។ ហើយសិទ្ធិលើបំណុលនេះត្រូវបានច្បាប់ទទួលស្គាល់នៅក្នុងនីតិខ្មែរចាប់តាំងពី ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ មកម្លេះ ក៏ប៉ុន្តែដោយសារតែក្នុងសម័យ ប៉ុល ពត ច្បាប់ត្រូវបានបំផ្លាញចោលទាំងអស់ទើបតម្រូវឱ្យប្រទេសកម្ពុជាយើងត្រូវបង្កើតនូវច្បាប់ថ្មីដើម្បីគ្រប់គ្រងទំនាក់ទំនងនេះ។ ដើម្បីឆ្លើយតបនឹងតម្រូវការនេះ ទើបប្រទេសកម្ពុជាយើងបានបង្កើតឱ្យមានក្រមរដ្ឋប្បវេណីថ្មីដែលត្រូវបានព្រះមហាក្សត្រឡាយព្រះហស្តលេខាកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧។

ទាក់ទងនឹងសិទ្ធិលើបំណុលយើងឃើញថា សិទ្ធិលើបំណុលមិនមានអត្ថិភាពស្ថិតស្ថេររហូតទេ គឺវាមានអាជ្ញាយុកាលដែលច្បាប់កំណត់ ហើយម្ចាស់បំណុលត្រូវអនុវត្តសិទ្ធិរបស់ខ្លួនក្នុងអំឡុងពេលនោះ បើមិនដូច្នេះទេ កាតព្វកិច្ចរបស់កូនបំណុលនឹងត្រូវរលត់ ហើយម្ចាស់បំណុលមិនអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចបានទៀតទេ។

កាលដែលក្រមរដ្ឋប្បវេណីបានកំណត់យ៉ាងដូច្នេះ គឺមិនចង់ឱ្យម្ចាស់បំណុលចេះតែលង់លក់ចំពោះសិទ្ធិរបស់ខ្លួន មិនរវីរវល់ទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច។ អំឡុងពេលអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលមានអំឡុងពេល ៥ឆ្នាំ គឺសមរម្យនឹងអាចទទួលយកបានទាំងម្ចាស់បំណុល និងកូនបំណុល។ មានន័យថាអំឡុងពេលនេះមិនយូរពេកសម្រាប់កូនបំណុល ហើយក៏មិនឆាប់ពេកសម្រាប់ម្ចាស់បំណុលដែរ។

ក៏ប៉ុន្តែ ទោះបីជាអំឡុងពេលនៃអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលមានអំឡុងពេលហួស ៥ឆ្នាំ ក៏ដោយ ប្រសិនបើអ្នកដែលមានសិទ្ធិលើកឡើងពីអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុលមិនបានលើកឡើងទេ តុលាការក៏មិនអាចលើកឡើងជំនួសជនទាំងនោះបានដែរ។ ចំណុចនេះមានការខុសប្លែកគ្នារវាងក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ច

សន្យា និងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ពោលគឺ ក្រឹត្យច្បាប់លេខ ៣៨ ប្រកាន់យកគោលការណ៍ថៅក្រមសកម្ម ចំណែកឯ ក្រមរដ្ឋប្បវេណីប្រកាន់យកគោលការណ៍ថៅក្រមអកម្ម។

នៅក្នុងសង្គមខ្មែរបច្ចុប្បន្នវិវាទទាក់ទងនឹងសិទ្ធិលើបំណុល និងកាតព្វកិច្ចកើតមានឡើងជាញឹកញាប់ ហើយពេលខ្លះទាំងភាគី ម្ចាស់បំណុល និងកូនបំណុលមិនដែលបានដឹងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយសារតែពួកគាត់ខ្វះការយល់ដឹងផ្នែកច្បាប់ទាក់ទងនឹងបញ្ហានេះ។ ពេលខ្លះទៀត កូនបំណុលមិនបានដឹងអំពីផលប្រយោជន៍នៃការលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដែលជាកត្តាធ្វើឱ្យខ្លួនបាត់បង់ផលប្រយោជន៍ដោយមិនដឹងខ្លួន។ ម្យ៉ាងវិញទៀត ពេលខ្លះពិតមែនតែអំឡុងពេលនៃអាជ្ញាយុកាលហួស ៥ឆ្នាំ ក៏ដោយ ក៏អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចដែរ ដោយសារតែមានមូលហេតុនៃការផ្អាក ឬការបង្អង់ការសម្រេចអាជ្ញាយុកាលនោះ។

ដូច្នេះដើម្បីជាប្រយោជន៍សម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗ ក៏ដូចជាអ្នកដែលចង់សិក្សាស្វែងយល់អំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិបំណុលក្នុងកិច្ចសន្យា ព្រមទាំងដើម្បីពង្រីកនូវចំណេះដឹងផ្ទាល់ខ្លួនទាក់ទងទៅនឹងបញ្ហានេះទើប ក្រុមរបស់ខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ « អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្នុងកិច្ចសន្យា» មកធ្វើការសិក្សាស្រាវជ្រាវរៀបរៀងជាស្នាដៃឡើង។

តើអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្នុងកិច្ចសន្យាមានអត្ថន័យ និងខ្លឹមសារយ៉ាងដូចម្តេច?

ប្រធានបទ «អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្នុងកិច្ចសន្យា» នេះគឺផ្តោតទៅលើក្របខណ្ឌច្បាប់ក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ។ ការបកស្រាយនឹងការពន្យល់នេះគឺអនុលោមតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ស្តីអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។

ថ្វីត្បិតតែការស្រាវជ្រាវនេះមានអំឡុងពេលខ្លី ពោលគឺត្រឹមតែមួយឆមាសក៏ពិតមែន ក៏ពួកយើងជឿជាក់ថាវាមានសារៈសំខាន់ចំពោះបងប្អូននិស្សិត ព្រមទាំងជនរួមជាតិគ្រប់រូប និងបណ្តាវិនិយោគគិន។ អ្វីដែលសំខាន់នោះគឺ ការអនុវត្តប្រកបដោយភាពឆ្លាតវៃ យុត្តិធម៌ សមភាព គ្មានបញ្ហាកើតឡើង។ លើសពីនេះទៅទៀត វាជាជំនួយដល់ការសិក្សាលើមុខវិជ្ជា និតិកាតព្វកិច្ច។

ដើម្បីឆ្លើយតបនឹងសំនួរគតិយុត្តិខាងលើ ប្រធានបទ «អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្នុងកិច្ចសន្យា» នេះនឹងត្រូវបានបកស្រាយដោយធ្វើការបែងចែកចេញជាពីរជំពូកដូចខាងក្រោមៈ

ជំពូកទី ១ សញ្ញាណទូទៅនៃអាជ្ញាយុកាល និងសិទ្ធិលើបំណុល

ជំពូកទី ២ យន្តការគតិយុត្តិនៃអាជ្ញាយុកាលលើការរំលត់សិទ្ធិលើបំណុល

ចំណោទបញ្ហាទាំងអស់ខាងលើនឹងត្រូវបានបង្ហាញនៅទំព័រខាងមុខជាបន្តបន្ទាប់ដូចតទៅៈ

# ជំពូកទី ១
# សញ្ញាណទូទៅនៃអាជ្ញាយុកាល និងសិទ្ធិលើបំណុល

ជាគោលការណ៍សិទ្ធិលើបំណុលមិនមានអត្ថិភាពជារៀងរហូតទេ គឺតែងតែមានអំឡុងពេលដែលកំណត់ដោយច្បាប់អាចឱ្យម្ចាស់បំណុលអនុវត្តសិទ្ធិរបស់ខ្លួនបាន ហើយប្រសិនបើម្ចាស់បំណុលមិនអនុវត្តសិទ្ធិរបស់ខ្លួនក្នុងអំឡុងពេលនោះទេ នោះច្បាប់ក៏មិនការពារឱ្យសិទ្ធិលើបំណុលមានអត្ថិភាពទៀតដែរ។ ដូច្នេះដើម្បីឱ្យម្ចាស់បំណុលខិតខំស្វះស្វែងរកមធ្យោបាយដើម្បីឱ្យសិទ្ធិលើបំណុលរបស់ខ្លួនបន្តមានអត្ថិភាព។ ខាងក្រោមនេះជាការបកស្រាយអំពីសញ្ញាណទូទៅនៃអាជ្ញាយុកាល ក៏ដូចជាសិទ្ធិលើបំណុល។

## ១.១. អាជ្ញាយុកាល

អាជ្ញាយុកាលគឺជាអំឡុងពេលមួយដែលកំណត់ដោយច្បាប់។ ការកន្លងហួសនៃអំឡុងពេលនេះបង្កើតឱ្យមានអានុភាពនៃលទ្ធកម្ម ឬការរំលត់សិទ្ធិណាមួយ។ ដូច្នេះអាជ្ញាយុកាលត្រូវបានបែងចែកជាពីរប្រភេទគឺ៖ អាជ្ញាយុកាលនៃលទ្ធកម្ម និងអាជ្ញាយុកាលនៃការរំលត់សិទ្ធិ។

### ១.១.១. អាជ្ញាយុកាលនៃលទ្ធកម្ម

#### ១.១.១.១. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិ

អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិត្រូវបានបែងចែកជាពីរ គឺអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ និងអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ។

##### ១.១.១.១.១. អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ

**ក. គោលគំនិត**

អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុត្រូវបានបញ្ញត្តឡើងដើម្បីដោះស្រាយនូវបញ្ហាខាងគតិយុត្តមួយចំនួនដែលបានបន្សល់ទុកនៅក្នុងសង្គមកម្ពុជា។ ឧទាហរណ៍ថា ប្រសិនបើការលក់ទិញអចលនវត្ថុដែលមិនបានធ្វើឡើងដោយលិខិតយថាភូត នោះមិនបង្កើតឱ្យមានអានុភាពគតិយុត្តឡើយ។ ក្នុងករណីនេះប្រសិនបើការលក់ទិញនោះធ្វើឡើងត្រឹមតែលិខិតឯកជនមានន័យថាអ្នកទិញនៅតែមិនអាចក្លាយជាកម្មសិទ្ធិករស្របច្បាប់ដដែល។ ចុះប្រសិនបើអ្នកទិញនោះបានកាន់កាប់អស់អំឡុងពេលយូរ ហើយអ្នកលក់ក៏បានទទួលមរណៈភាព ឬចាកចេញទៅ

ក្រៅប្រទេស តើនរណាអាចផ្ទេរកម្មសិទ្ធិបាន? ដូចនេះមានតែរបបស្តីពីអាជ្ញាយុកាលទេ ដែលអាចដោះស្រាយបាន។

ម្យ៉ាងទៀតនៅក្នុងរបបសេដ្ឋកិច្ចទីផ្សារសេរី ការប្រើប្រាស់វត្ថុគឺជាយន្តការមួយដែលអាចធ្វើឱ្យសេដ្ឋកិច្ចរីកចម្រើន។ ប្រសិនបើម្ចាស់កម្មសិទ្ធិមិនបានប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួនទេវាក៏អាចប៉ះពាល់ដល់បំលាស់ប្តូរនៃសេដ្ឋកិច្ចដែរ។ ដូចនេះរបបស្តីពីអាជ្ញាយុកាលនៃលទ្ធកម្មក៏ជាការដាក់ទណ្ឌកម្មដល់ម្ចាស់កម្មសិទ្ធិដែលភ្លេចខ្លួនមិនបានប្រើប្រាស់ទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីជាប្រយោជន៍ដល់សង្គម។

### ខ. និយមន័យ

អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិ កើតឡើងដោយសារពាក្យ អាជ្ញាយុកាល និងពាក្យលទ្ធកម្មកម្មសិទ្ធិ។

-ពាក្យ **អាជ្ញាយុកាល** នៅចំណុចនេះមានន័យថាជាអំឡុងពេលមួយដែលផ្តល់ឱ្យអ្នកកាន់កាប់អាចទទួលបាននូវ កម្មសិទ្ធិ[1]។

-ពាក្យ **លទ្ធកម្មកម្មសិទ្ធិ** មានន័យថាជាការទទួលបាន ឬ ក្លាយជាម្ចាស់កម្មសិទ្ធិនៃវត្ថុណាមួយ ដោយការងាររបស់ខ្លួនក្តី ដោយទិញ ឬដោយដូរក្តី[2]។

ដូច្នេះពាក្យអាជ្ញាយុកាលនៃលទ្ធកម្មគឺជាអំឡុងពេលមួយដែលផ្តល់ឱ្យអ្នកកាន់កាប់អាចទទួលបាននូវ កម្មសិទ្ធិតាមរយៈការកាន់កាប់របស់ខ្លួនតាមលក្ខខណ្ឌដែលច្បាប់តម្រូវ។ ដើម្បីទទួលបាននូវកម្មសិទ្ធិ អ្នកកាន់កាប់ត្រូវគោរពលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់[3]។ លក្ខខណ្ឌទាំងនោះរួមមាន៖ លក្ខខណ្ឌអាជ្ញាយុកាលសម្រាប់រយៈខ្លី និង សម្រាប់អំឡុងពេលវែង។

### គ. លក្ខខណ្ឌអាជ្ញាយុកាលលទ្ធកម្មកម្មសិទ្ធិ

ដើម្បីទទួលបាននូវកម្មសិទ្ធិ អ្នកកាន់កាប់ត្រូវបំពេញនូវលក្ខខណ្ឌដែលច្បាប់តម្រូវ ហើយលក្ខខណ្ឌនោះមានអំឡុងពេលវែង និងអំឡុងពេលខ្លី អាស្រ័យលើភាពសុចរិត ឬភាពទុចរិត និងមានកំហុស ឬគ្មានកំហុស។

[1] សន្ទានុក្រមនៃក្រមរដ្ឋប្បវេណី ចំណុច១៩៦
[2] សន្ទានុក្រមនៃក្រមរដ្ឋប្បវេណី ចំណុច១៣០
[3] មាត្រា ១៦២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

**អំឡុងពេលខ្លី:**

ជនដែលបានកាន់កាប់អចលនវត្ថុ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោមនេះ ៖

- ភាពសុចរិត និងគ្មានកំហុស
- សន្តិវិធី
- ដឹងឮជាសាធារណៈ
- មានឆន្ទៈយកជាកម្មសិទ្ធិ
- កាន់កាប់ក្នុងអំឡុងពេល ១០ឆ្នាំ
- ការលើកឡើងនូវអាជ្ញាយុកាល។

**អំឡុងពេលវែង:**

ជនដែលបានកាន់កាប់អចលនវត្ថុ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ៖

- សន្តិវិធី
- ដឹងឮជាសាធារណៈ
- មានឆន្ទៈយកជាកម្មសិទ្ធិ
- កាន់កាប់ក្នុងអំឡុងពេល ២០ឆ្នាំ
- ការលើកឡើងនូវអាជ្ញាយុកាល។

**១.១.១.១.២. អាជ្ញាយុកាលលទ្ធកម្មសិទ្ធិលើចលនវត្ថុ**

នៅក្នុងសេដ្ឋកិច្ចទីផ្សារសេរី ចលនវត្ថុត្រូវបានគេជួញដូរជាញឹកញាប់ ហើយដើម្បីរក្សានូវសុវត្ថិភាពខាងជំនួញ ក្រមរដ្ឋប្បវេណីបានបញ្ញត្តទាក់ទងទៅនឹងលទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ។ ម្យ៉ាងទៀត ចលនវត្ថុត្រូវបានផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិ ឬធ្វើអនុប្បទានពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតជាញឹកញាប់។ ដូច្នេះដើម្បីការពារជនដែលបានធ្វើការកាន់កាប់ដោយសុច្ចរិត និងគ្មានកំហុស ក្រមរដ្ឋប្បវេណីបានបញ្ញត្តតម្រូវឱ្យមានលក្ខខណ្ឌមួយចំនួនដើម្បីអាចធ្វើលទ្ធកម្មដោយសុច្ចរិតនូវចលនវត្ថុដូចខាងក្រោម៖

- កាន់កាប់ដោយសន្តិវិធី
- ដឹងឮជាសាធារណៈ
- មានឆន្ទៈយកធ្វើជាកម្មសិទ្ធិ

- កាន់កាប់អំឡុងពេល ០៥ឆ្នាំ[4]។

ក្នុងករណីខាងលើនេះ ប្រសិនបើជននោះបានធ្វើការកាន់កាប់ដោយទុច្ចរិត និងមានកំហុសនៅពេលដែលខ្លួនចាប់ផ្ដើមកាន់កាប់ ជននោះអាចធ្វើលទ្ធកម្មកម្មសិទ្ធិក្នុងអំឡុងពេល ១០ឆ្នាំ[5]។

### ១.១.១.២. អាជ្ញាយុកាលលទ្ធកម្មសិទ្ធិ

#### ១.១.១.២.១. អាជ្ញាយុកាលលទ្ធកម្មសិទ្ធិទាក់ទងនឹងអចលនវត្ថុ

ជនដែលបានប្រើសិទ្ធិរបស់ខ្លួនទាក់ទងនឹងអចលនវត្ថុដែលសិទ្ធិទាំងនោះរួមមាន៖ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ និងសិទ្ធិអាស្រ័យនៅ សិទ្ធិជួល សិទ្ធិលើការបញ្ចាំ សុទ្ធតែអាចធ្វើលទ្ធកម្មនូវសិទ្ធិទាំងនោះបាន ដោយគ្រាន់តែប្រើប្រាស់សិទ្ធិនោះ ដោយសន្តិវិធី ដឹងឮជាសាធារណៈ ដោយមានឆន្ទៈប្រើសម្រាប់ខ្លួន ត្រូវលទ្ធកម្មនូវសិទ្ធិនោះក្រោយពេល ២០ឆ្នាំ ហើយប្រសិនបើជននោះជាដែលសុច្ចរិត និងគ្មានកំហុស អំឡុងពេលនេះត្រូវបន្ថយមកត្រឹម ១០ឆ្នាំ[6]។

#### ១.១.១.២.២. អាជ្ញាយុកាលលទ្ធកម្មសិទ្ធិទាក់ទងនឹងចលនវត្ថុ

ជនដែលបានប្រើសិទ្ធិរបស់ខ្លួនទាក់ទងនឹងចលនវត្ថុដែលសិទ្ធិទាំងនោះរួមមាន៖ សិទ្ធិលើការបញ្ចាំ សិទ្ធិជួលដោយសន្តិវិធី និងដឹងឮជាសាធារណៈ ដោយមានឆន្ទៈប្រើសម្រាប់ខ្លួនត្រូវលទ្ធកម្មនូវសិទ្ធិនោះក្រោយពេល ១០ឆ្នាំ ហើយប្រសិនបើជននោះជាជនសុច្ចរិត និងគ្មានកំហុសអំឡុងពេលនេះត្រូវបន្ថយមកត្រឹម ៥ឆ្នាំ ដោយគោរពលក្ខខណ្ឌតាមបញ្ញត្តិនៃមាត្រា ១៩៥ នៃក្រមរដ្ឋប្បវេណី។

[4] ចំពោះលក្ខខណ្ឌនៃអាជ្ញាយុកាល ដើម្បីទទួលលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុដូចគ្នានឹងលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ ខុសគ្នាតែអំឡុងពេលតែប៉ុណ្ណោះ

[5] មាត្រា ១៩៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[6] មាត្រា ១៧៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

### ១.១.២ អាជ្ញាយុកាលនៃការរំលត់សិទ្ធិ

#### ១.១.២.១ និយមន័យ

បើយោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ ១៩២០ បកប្រែដោយលោក អេង សុត អាជ្ញាយុកាលនៃការរំលត់សិទ្ធិបំណុល គឺបណ្តាលមកពីម្ចាស់បំណុលមិនបានប្តឹងអស់កាលជាអង្វែងពេក[7]។

តែបើយោងទៅតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅលើការរំលត់សិទ្ធិលើបំណុលដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិក្នុងអំឡុងពេលដែលត្រូវបានកំណត់[8]។

#### ១.១.២.២. ប្រភេទអាជ្ញាយុកាលរំលត់សិទ្ធិ

#### ១.១.២.២.១. អាជ្ញាយុកាលរំលត់សិទ្ធិក្នុងកិច្ចសន្យា

អាជ្ញាយុកាលនៃការរំលត់សិទ្ធិក្នុងកិច្ចសន្យាគឺជាអំឡុងពេលដែលកំណត់ដោយច្បាប់ដែលតម្រូវឱ្យភាគីដែលមានសិទ្ធិអាចអនុវត្តសិទ្ធិរបស់ខ្លួននៅក្នុងអំឡុងពេលដែលច្បាប់កំណត់នោះ។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិនៅក្នុងកិច្ចសន្យារួមមានៈ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានអំឡុងពេល ៥ឆ្នាំគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលបាន[9]។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិរំលាយកិច្ចសន្យាដោយមូលហេតុនៃការមិនអនុវត្តកាតព្វកិច្ច និងសិទ្ធិទាមទារបដិទានមានអំឡុងពេល ៥ឆ្នាំ ក្រោយពីពេលដែលមិនអនុវត្តកាតព្វកិច្ច[10]។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឱ្យសងការខូចខាត ដោយសារការមិនអនុវត្តកាតព្វកិច្ចមានអំឡុងពេល ៥ឆ្នាំក្រោយពេលដែលការខូចខាតនោះបានកើតឡើង[11]។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលុបចោលកិច្ចសន្យាមានអំឡុងពេល ៣ឆ្នាំចាប់តាំងពីពេលដែលខ្លួនក្លាយទៅជាអ្នកដែលអាចផ្តល់សច្ចានុមតិ។ ប្រសិនបើហួសអំឡុងពេល ១០ឆ្នាំ ចាប់តាំងពីកាលបរិច្ឆេទនៃសកម្មភាព នោះសិទ្ធិលុបចោលក៏ត្រូវរលត់ដែរ[12]។

---

[7] មាត្រា ៩២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ បកប្រែដោយលោក អេង សុត

[8] មាត្រា ៤៨០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[9] មាត្រា៤៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[10] មាត្រា៩១៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[11] មាត្រា ៤០៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

#### ១.១.២.២.២. អាជ្ញាយុកាលរំលត់សិទ្ធិក្រៅកិច្ចសន្យា

អាជ្ញាយុកាលនៃការរំលត់សិទ្ធិក្រៅកិច្ចសន្យាកើតឡើងដោយសារអ្នកដែលមានសិទ្ធិទាមទារសំណងការខូចខាត មិនបានអនុវត្តសិទ្ធិទាមទារសំណងការខូចខាតរបស់ខ្លួន ក្នុងអំឡុងពេល ៣ឆ្នាំបន្ទាប់ពីជនរងគ្រោះ ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះបានដឹងថាខ្លួនអាចទាមទារសំណងការខូចខាតចំពោះអ្នកដែលប្រព្រឹត្តអំពើបំពាន។ ម៉្យាងទៀត ប្រសិនបើហួសអំឡុងពេល ១០ឆ្នាំ បន្ទាប់ពីពេលដែលអំពើអនីត្យានុកូលត្រូវបានប្រព្រឹត្ត ជននោះក៏មិនអាចទាមទារសំណងការខូចខាតបានទៀតដែរ[13]។

## ១.២. សិទ្ធិលើបំណុល

### ១.២.១. ប្រវត្តិនៃសិទ្ធិលើបំណុល

តាមពិតទៅសិទ្ធិលើបំណុលមានប្រវិត្តតាំងពីពេលដែលមនុស្សចេះដូញដូរ ចេះធ្វើបំលាស់ប្តូរទំនិញទៅវិញទៅមក ក៏ប៉ុន្តែគ្រាន់តែសិទ្ធិនោះ នៅតែជាទម្លាប់នៅក្នុងសង្គម ហើយមិនទាន់ត្រូវបានបញ្ចូលទៅក្នុងច្បាប់នៅឡើយ។ មកដល់ឆ្នាំ ១៩២០ ដែលជាកំណើតក្រមរដ្ឋប្បវេណីកម្ពុជាលើកដំបូង សិទ្ធិលើបំណុលត្រូវបានបញ្ចូលទៅក្នុងនីតិវិជ្ជមាន និងមានការវិវត្តន៍រហូតមកដល់ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។

#### ១.២.១.១. ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ បកប្រែដោយលោក អេខ សុត ឆ្នាំ ១៩៦៧

សិទ្ធិលើបំណុលត្រូវបានគេរកឃើញនៅក្នុងនីតិខ្មែរដែលបញ្ញត្តនៅក្នុងគន្ថីទី ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០។ ពិសេសជាងនេះទៅទៀត នៅក្នុងក្រមនេះក៏បានបញ្ញត្តអំពីអាជ្ញាយុកាលនៃការរំលត់កាតព្វកិច្ចដែលមានចែងចាប់ពីមាត្រា ៩២៨ ដល់មាត្រា ៩៣៥ នៃក្រមនេះ ។ ក៏ប៉ុន្តែក្រមនេះមិនបានបញ្ញត្តអំពីមូលហេតុនៃការផ្អាក ឬ ការបង្អង់ឱ្យបានច្បាស់លាស់ដូចក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ មានន័យថាមូលហេតុនៃការផ្អាក ឬការបង្អង់នោះបានកំណត់ដែរ ប៉ុន្តែអាចមានការប្រែប្រួលខុសពីក្រមរដ្ឋប្បវេណី២០០៧ខ្លះៗ ។ ម៉្យាងទៀតចំណុចដែលគួរឱ្យចាប់អារម្មណ៍នោះ ក្រមនេះបានបញ្ញត្តអំពីគោលការណ៍ថៅក្រមអកម្មដូចក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ដែរពោលគឺ តុលាការមិនអាចលើកឡើងពីអាជ្ញាយុកាលដោយឯកឯងជំនួសសមីខ្លួនបានឡើយ។

---

[12] មាត្រា ៣៦៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[13] មាត្រា ៧៦៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ក្រោយមកសិទ្ធិលើបំណុលក៏ត្រូវបានប្រទះឃើញនៅក្នុងអត្ថបទច្បាប់មួយទៀតដែលមានដូចខាងក្រោម។

### ១.២.១.២. ក្រឹត្យច្បាប់លេខ ៣៨

ក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យច្បាប់ និងបទដ្ឋានគតិយុត្តិដទៃទៀតត្រូវបានបំផ្លាញចោលទាំងអស់ ដើម្បីជាជំនួយក្នុងការអភិវឌ្ឍប្រទេសជាតិឡើងវិញ ក្រុមប្រឹក្សារដ្ឋនៃសាធារណៈប្រជាមានិតកម្ពុជាបានសម្រេចបង្កើតក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ដែលអាចឱ្យយើងស្វែងរកនូវសិទ្ធិលើបំណុលដែលមានចែងនៅក្នុងជំពូកទី១ នៃក្រឹត្យច្បាប់នេះ ក៏ដូចជាជំពូកទី២ ផងដែរ។ ជាពិសេសក្រឹត្យច្បាប់នេះក៏បានបញ្ញត្តអំពីអាជ្ញាយុកាលនៃកិច្ចសន្យាដែលមានចែងនៅក្នុងផ្នែកទី៥ ចាប់ពីមាត្រា២៥ ដល់ មាត្រា២៨ នៃក្រឹត្យច្បាប់នេះ។ ក៏ប៉ុន្តែក្រឹត្យច្បាប់នេះមិនបានចែងឱ្យបានលម្អិតច្បាស់លាស់ពីការបង្អង់ ឬការផ្អាកដូចក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ទេ។ ម៉្យាងទៀតអ្វីដែលកាន់តែខុសប្លែកគ្នានោះគឺ ក្រឹត្យច្បាប់នេះប្រកាន់យកគោលការណ៍ថៅក្រមសកម្ម ពោលគឺ តុលាការអាចលើកឡើងនូវអាជ្ញាយុកាលជំនួសកូនបំណុលបាន។ ប្រហែលជានីតិករខ្មែរគិតថាសម័យនោះទើបតែរួចផុតពីសង្គ្រាមប្រជាពលរដ្ឋមិនសូវយល់ដឹងអំពីច្បាប់ ហើយមិនសូវសម្បូរមេធាវី ទើបឱ្យតុលាការជួយសម្រេចជំនួស។ ថ្វីត្បិតតែមានចំនុចខុសគ្នាក៏ពិតមែន តែអំឡុងពេលនៃការរលត់សិទ្ធិលើបំណុលនៅក្នុងក្រឹត្យច្បាប់នេះមានអំឡុងពេល ៥ឆ្នាំដូចក្រមរដ្ឋប្បវេណីដែរ។

### ១.២.១.៣. ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

បច្ចុប្បន្នប្រទេសកម្ពុជាកំពុងអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក្រមនេះត្រូវបានបង្កើតឡើងដោយទទួលបានជំនួយពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន ដែលត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី ៥ ខែតុលា ឆ្នាំ២០០៧ និងព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើនៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០០៧ ដែលមានបញ្ញត្តទាក់ទងនឹងសិទ្ធិលើបំណុលនៅក្នុងគន្ថីទី៤ (កាតព្វកិច្ច) និង គន្ថី ទី៥ (កិច្ចសន្យាសំខាន់ និងអំពើអនីត្យានុកូល)។ ជាពិសេសនៅក្នុងជំពូកទី៨ នៃគន្ថីទី ៤បានបញ្ញត្តអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដែលមានលក្ខណៈ កាន់តែលម្អិត និងច្បាស់លាស់ជាងអត្ថបទច្បាប់មុនៗ។ ជាក់ស្តែងក្រមនេះបានចែងលម្អិតអំពីការផ្អាក និងការបង្អង់អាជ្ញាយុកាលនៃការរំលត់លើបំណុល ក៏ប៉ុន្តែក្រមនេះបានប្រកាន់យកគោលការណ៍ថៅក្រមអកម្ម ពោលគឺតុលាការមិនអាចលើកឡើង នូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជំនួសកូនបំណុលបានឡើយ។ អ្វីដែលគួរឱ្យគត់សម្គាល់នោះគឺ ទាំងក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០

និងក្រឹត្យច្បាប់លេខ ៣៨ ក៏ដូចជាក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ អំឡុងពេលរំលត់សិទ្ធិលើបំណុល សុទ្ធតែមានអំឡុងពេល ៥ឆ្នាំដូចគ្នា។

### ១.២.២. ប្រភពសិទ្ធិលើបំណុល

ដោយសារតែសិទ្ធិលើបំណុល និងកាតព្វកិច្ចមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ពោលគឺ ប្រសិនបើភាគីម្ខាងមានសិទ្ធិលើបំណុល នោះនាំឱ្យភាគីម្ខាងទៀតមានកាតព្វកិច្ចនៅក្នុងទំនាក់ទំនងនេះ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា ប្រភពនៃសិទ្ធិលើបំណុល គឺដូចគ្នាទៅនឹងប្រភពនៃកាតព្វកិច្ចដែរ។ ប្រភពនៃសិទ្ធិលើបំណុលរួមមាន កិច្ចសន្យា សកម្មភាពឯកតោភាគី សេចក្ដីចម្រើនដោយឥតហេតុ ការគ្រប់គ្រងដោយឈឺឆ្អាល អំពើអនីត្យានុកូល និងបញ្ញត្តច្បាប់។

#### ១.២.២.១. កិច្ចសន្យា

កិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ច[14]។

កិច្ចសន្យាត្រូវបានបង្កើតឡើងដោយឈរលើគោលការណ៍ស្វ័យភាពឆន្ទៈនៃបុគ្គលឯកជន[15]

ឧទាហរណ៍: លោក ក បានធ្វើកិច្ចសន្យាលក់ ទិញរថយន្តជាមួយលោក ខ។

#### ១.២.២.២. សកម្មភាពឯកតោភាគី

សកម្មភាពឯកតោភាគីគឺជាសកម្មភាពដែលបង្កើត កែប្រែ ឬរំលត់នូវកាតព្វកិច្ចដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬតាមបញ្ញត្តិច្បាប់[16]។

ឧទាហរណ៍: លោក ក បានធ្វើអច្ច័យទាននូវទ្រព្យសម្បត្តិមួយចំនួនទៅឱ្យ លោក ខ។

#### ១.២.២.៣. ការគ្រប់គ្រងដោយឈឺឆ្អាល

ការគ្របគ្រងដោយឈឺឆ្អាលគឺជា ការចាប់ផ្ដើមគ្រប់គ្រងកិច្ចការដើម្បីបុគ្គលដទៃ ទោះបីជាគ្មានសិទ្ធិអំណាចក៏ដោយ។ អ្នកដែលធ្វើការគ្រប់គ្រងដោយឈឺឆ្អាលហៅថា អ្នកគ្រប់គ្រងដោយឈឺឆ្អាល។ អ្នកគ្រប់គ្រងដោយឈឺឆ្អាល ត្រូវគ្រប់គ្រងដោយព្យាយាមប្រុងប្រយ័ត្ន ក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត តាមវិធីដែលសមរម្យជាងគេ ដើម្បីផលប្រយោជន៍របស់សាមីខ្លួន ផ្អែកតាម

[14] មាត្រា ៣១១ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

[15] មាត្រា ៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[16] មាត្រា ៣១២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

លក្ខណៈនៃកិច្ចការនោះ។ ប្រសិនបើអ្នកគ្រប់គ្រងដោយឈឺឆ្អាល បានដឹងអំពីឆន្ទៈរបស់សាមីខ្លួន ឬប្រសិនបើអាចដឹងអំពីឆន្ទៈនោះបាន ត្រូវធ្វើការគ្រប់គ្រងដោយផ្អែកតាមឆន្ទៈនោះ។

ឧទាហរណ៍: លោក ក បានទៅលេងអង្គរសង្ក្រាននៅសៀមរាប ស្រាប់តែមានភ្លៀងមក លោក ខ ដែលជាអ្នកជិតខាងឃើញដំបូលផ្ទះរបស់លោក ក លិចទឹក ក៏បានធ្វើការជួសជុល។

#### ១.២.២.៤. សេចក្តីចំរើនឥតហេតុ

សេចក្តីចំរើនឥតហេតុ គឺជាការទទួលបានផលប្រយោជន៍ដោយគ្មានមូលហេតុលើផ្លូវច្បាប់ បុគ្គលដែលបានទទួលផលប្រយោជន៍ដោយសារទ្រព្យសម្បត្តិ ឬពលកម្មរបស់អ្នកដទៃ ត្រូវមានករណីកិច្ចសងផលប្រយោជន៍ត្រឹមកម្រិតនោះ។

ឧទាហរណ៍: ការសងដោយច្រឡំ ថាជាកាតព្វកិច្ចរបស់ខ្លួន។

#### ១.២.២.៥. បញ្ញាត្តិច្បាប់

ប្រភពនៃកាតព្វកិច្ចដែលកំណត់ដោយច្បាប់គឺអាស្រ័យទៅតាមបញ្ញាត្តដែលច្បាប់កំណត់។ ប្រសិនបើច្បាប់ចែងថាប្រជាពលរដ្ឋ ឬមនុស្សមួយក្រុមណាមួយមានកាតព្វកិច្ចអ្វីមួយ នោះរដ្ឋជាម្ចាស់បំណុលលើប្រជាពលរដ្ឋ ឬមនុស្សមួយក្រុមនោះ។

ឧទាហរណ៍: ការបង់ពន្ធជូនរដ្ឋ មានន័យថារដ្ឋជាម្ចាស់បំណុល។

### ១.២.៣. ទំនាក់ទំនងសិទ្ធិលើបំណុល និងកាតព្វកិច្ច

កាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ ឬច្រើននាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់មានករណីកិច្ចមួយចំនួន ចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។ សិទ្ធិលើបំណុល គឺជាសិទ្ធិដែលទាមទារឱ្យបុគ្គលណាម្នាក់ធ្វើសកម្មភាពដើម្បីជាប្រយោជន៍ខ្លួន។ សិទ្ធិលើបំណុល និងកាតព្វកិច្ចមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនៅក្នុងទំនាក់ទនងបុគ្គលឯកជន។ នៅក្នុងទំនាក់ទំនងគតិយុត្តមួយមិនអាចមានតែសិទ្ធិ ឬកាតព្វកិច្ចទេ ព្រោះថាបុគ្គលដែលមានសិទ្ធិលើបំណុល គឺជាបុគ្គលដែលទទួលផលប្រយោជន៍ រីឯបុគ្គលដែលមានកាតព្វកិច្ច គឺជាបុគ្គលដែលបាត់បង់ផលប្រយោជន៍ [17] ។ ទំហំនៃសិទ្ធិលើបំណុល និងកាតព្វកិច្ចត្រូវតែសមាមាត្រគ្នា ព្រោះកាតព្វកិច្ចរបស់កូនបំណុល ត្រូវគ្នាជាមួយសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល។ នៅក្នុងទំនាក់ទំនងគតិយុត្តមួយបើគ្មានកាតព្វកិច្ចទេ ក៏គ្មានសិទ្ធិលើបំណុលដែរ គ្មានអ្នកដែលធ្វើសកម្មភាពដើម្បីជាផលប្រយោជន៍ឱ្យម្ចាស់បំណុល។

[17] មាត្រា ៣០៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ឧទាហរណ៍: នៅក្នុងកិច្ចសន្យាលក់ទិញ អ្នកលក់ត្រូវមានករណីកិច្ចប្រគល់នូវវត្ថុដែលជាកម្មវត្ថុនៃការលក់ឱ្យអ្នកទិញ។ ដូច្នេះ អ្នកលក់ជាកូនបំណុលដែលមានកាតព្វកិច្ច ឯអ្នកទិញជាម្ចាស់បំណុលដែលមានសិទ្ធិលើបំណុល នៅក្នុងការប្រគល់វត្ថុ។ ហើយកាតព្វកិច្ចដែលអ្នកលក់ត្រូវបំពេញ គឺប្រគល់វត្ថុ (ការបាត់បង់ផលប្រយោជន៍) អ្នកទិញមានសិទ្ធិទទួលបាននូវវត្ថុ(ការទទួលបាននូវផលប្រយោជន៍) ។ ម្យ៉ាងទៀត ការប្រគល់នូវវត្ថុរបស់អ្នកលក់ និងការទទួលវត្ថុរបស់អ្នកទិញ គឺជាវត្ថុតែមួយ មិនមែនអ្នកលក់ប្រគល់វត្ថុផ្សេង ហើយអ្នកទិញទទួលបានវត្ថុផ្សេងនោះទេ នោះសិទ្ធិ និងកាតព្វកិច្ចគ្មានទំនាក់ទំនងគ្នាទេ។

# ជំពូកទី ២

# យន្តការគតិយុត្តិនៃអាជ្ញាយុកាល

# នៃការរំលត់សិទ្ធិលើបំណុល

# ជំពូកទី ២

# យន្តការគតិយុត្តិនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលគឺជារបបគតិយុត្តិមួយដែលមានបញ្ញត្តនៅក្នុងក្រមរដ្ឋប្បវេណី ដែលបញ្ញត្តិនោះមានកំណត់អំពីអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ពេលចាប់ផ្តើមអ្នកដែលមានសិទ្ធិលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ការផ្អាក និងការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ នៅក្នុងជំពូកនេះនឹងមានការបង្ហាញអំពីសញ្ញាណទូទៅនៃការរំលត់សិទ្ធិលើបំណុល ការផ្អាក និងការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ព្រមទាំងហេតុដែលមិននាំឱ្យមានការផ្អាក និងការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។

## ២.១. សញ្ញាណទូទៅនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

### ២.១.១. គោលគំនិត

យើងបានសិក្សារួចមកហើយអំពីអាជ្ញាយុកាលនៃលទ្ធកម្ម ដូច្នេះគោលគំនិតអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុល ក៏មានលក្ខណៈ និងគោលគំនិតមិនខុសគ្នាប៉ុន្មានទេ។ សំនួរចោទសួរថា ចុះហេតុអ្វីចាំបាច់បញ្ញត្តឱ្យមានអាជ្ញាយុកាលនៃការរំលត់សិទ្ធិបំណុល?

មានហេតុផលមួយចំនួនដែលជំរុញឱ្យនីតិករខ្មែរតាំងពីសម័យមានកំណារកំណើតក្រមរដ្ឋប្បវេណីលើកដំបូងនៅឆ្នាំ ១៩២០ រហូតមកដល់ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានសម្រេចបញ្ចូលឱ្យមានបញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់លើបំណុល។ ហេតុផលទាំងនោះរួមមាន៖

#### ២.១.១.១. ស្ថេរភាព និងការថែរក្សានូវសណ្តាប់ធ្នាប់សង្គម

ប្រសិនបើមិនមានការកំណត់ពេលឱ្យបានច្បាស់លាស់អំពីអត្ថិភាពនៃសិទ្ធិលើបំណុលនោះទេ នាំឱ្យមានការបង្កើតនូវទំនាក់ទំនងគតិយុត្តិផ្សេងៗទៀតក្រៅពីសិទ្ធិលើបំណុលនេះ ដែលអាចមានឋានៈដូចគ្នា តែមានបុគ្គលផ្សេងគ្នាទៅវិញ ហើយឈានទៅដល់មានវិវាទអំពីសិទ្ធិលើបំណុលតែមួយដូចគ្នា ចំពោះកូនបំណុលតែម្នាក់ ។ ដូច្នេះនឹងនាំឱ្យគ្មានស្ថេរភាពគតិយុត្តិ ដោយសារតែពិបាកក្នុងការការពារឋានៈរបស់បុគ្គលនីមួយដែលមានវិវាទនឹងគ្នា។

ឧទាហរណ៍: លោក ក ជាម្ចាស់សិទ្ធិលើបំណុលចំពោះលោក ខ ប្រសិនបើច្បាប់មិនបានកំណត់អំពីអំឡុងពេលអត្ថិភាពនៃសិទ្ធិលើបំណុលឱ្យបានច្បាស់លាស់ទេ ដោយទុកអំឡុងពេល

អូសបន្លាយយូរពេក នាំឱ្យអាចមានភាពច្របូកច្របល់ដោយសារតែ អាចមានការបង្កើតឋានៈជាម្ចាស់សិទ្ធិលើបំណុល លោក គ ចំពោះលោក ខ ហេតុដូច្នេះហើយដើម្បីបញ្ចៀសនូវការលុបចោលនូវសកម្មភាពដែលមានអំឡុងពេលវែងពេក ទើបបញ្ញត្តឱ្យមានអំឡុងពេលកំណត់ត្រឹម ៥ឆ្នាំ។

**២.១.១.២. បន្ថយនូវបញ្ហាលំបាកនៃការប្រមូលភស្តុតាង**

យើងដឹងស្រាប់ហើយថា បើកាលណាអំឡុងពេលកាន់តែយូរ នោះភស្តុតាងក៏ដូចជាឯកសារផ្សេងៗ ដូចជាកិច្ចសន្យា អាចនឹងងាយស្រួលក្នុងការបាត់បង់ ឬខូចខាតដោយសារតែពេលខ្លះមានភាពលំបាកក្នុងការរក្សាទុកភស្តុតាងដែលបញ្ជាក់អំពី អត្ថិភាពនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល ហើយប្រការនេះអាចធ្វើឱ្យម្ចាស់បំណុលប្រឈមមុខនឹងហានិភ័យ មិនអាចបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិលើបំណុលរបស់ខ្លួននូវចំពោះមុខតុលាការ ក្នុងករណីដែលកូនបំណុលមានគំនិតទុច្ចរិតក្នុងការគេចវេស មិនអនុវត្តកាតព្វកិច្ច។ ដូច្នេះនីតិករខ្មែរបានគិតគូរយ៉ាងយកចិត្តទុកដាក់ទៅលើអំឡុងពេលមួយ ដែលអាចសន្មតថាសមរម្យអាចឱ្យម្ចាស់បំណុលរក្សាទុកនូវភស្តុតាងដែលបញ្ជាក់ អំពីសិទ្ធិលើបំណុលបានគង់វង្ស ហើយតុលាការក៏ងាយស្រួលក្នុងការពិនិត្យភស្តុតាងពាក់ព័ន្ធនឹងបណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិលើបំណុល។ ដូច្នេះហើយ ទើបយើងឃើញថាទាំងក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ និង ក្រឹត្យច្បាប់លេខ ៣៨ ក៏ដូចជាក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ កំណត់អំឡុងពេលនៃអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលត្រឹមតែ ៥ឆ្នាំ។

**២.១.១.៣. ដាស់តឿនចំពោះជនដែលលង់លក់នឹងសិទ្ធិ**

ជាទូទៅច្បាប់តែងតែកំណត់អំឡុងពេលឱ្យបុគ្គលណាម្នាក់អាចអនុវត្តសិទ្ធិរបស់ខ្លួនបានក្នុងអំឡុងពេលមួយជាកំណត់ មិនមែនចេះតែអនុវត្តសិទ្ធិរបស់ខ្លួនតាមតែចិត្តនឹកឃើញរបស់ខ្លួននោះទេ ព្រោះថាប្រសិនបើបុគ្គលម្នាក់ៗ ចេះតែលង់លក់នឹងទ្រឹស្តីសិទ្ធិនិយមខ្លាំងពេក វានាំឱ្យខ្លួនធ្វេសប្រហែសមិនអនុវត្តសិទ្ធិរបស់ខ្លួន។ ហើយការមិនអនុវត្តសិទ្ធិនេះវាអាចប៉ះពាល់ដល់ចរន្តផ្លាស់ប្តូរនៃរបបសេដ្ឋកិច្ចទីផ្សារសេរី ព្រោះបើម្ចាស់បំណុលមិនអនុវត្តសិទ្ធិរបស់ខ្លួន នាំឱ្យដើមទុនរបស់ខ្លួនកប់ដើម មិនអាចបង្វិលទៅវិនិយោគលើវិស័យផ្សេងៗ ហើយនាំឱ្យមានឱនភាពសេដ្ឋកិច្ចជាតិ។ ដូច្នេះដើម្បីជាការបញ្ជាក់ស្មារតី ក៏ដូចជាការដាក់ទណ្ឌកម្មដល់ជនដែលមិនព្រមអនុវត្តសិទ្ធិរបស់ខ្លួនក្នុងអំឡុងពេល ៥ឆ្នាំនោះ។

**២.១.២. និយមន័យ**

**២.១.២.១. អាជ្ញាយុកាល**

យោងតាមសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ អាជ្ញាយុកាល គឺជាមធ្យោបាយម្យ៉ាងសម្រាប់ដោះខ្លួនឱ្យរួចផុតពីកាតព្វកិច្ចណាមួយ កាលបើម្ចាស់កាតព្វកិច្ចនោះបណ្ដែតបណ្ដោយឱ្យជំពាក់យូរពេកមិនតឹងទារ[18]។

យោងតាមសន្ទានុក្រមនៃច្បាប់ភូមិបាលឆ្នាំ ២០០១ អាជ្ញាយុកាល គឺជាមធ្យោបាយម្យ៉ាងសម្រាប់ដោះខ្លួនឱ្យរួចផុតពីកាតព្វកិច្ចណាមួយ កាលបើម្ចាស់កាតព្វកិច្ចនោះបណ្ដែតបណ្ដោយឱ្យជំពាក់យូរពេក។

យោងតាមសន្ទានុក្រមនៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ចំនុចទី១៩៦ អាជ្ញាយុកាល គឺជាអំឡុងពេលមួយដែលកំណត់ដោយច្បាប់។ ការកន្លងហួសនៃអំឡុងពេលនេះ បង្កើតឱ្យមានអានុភាពនៃលទ្ធកម្ម ឬការរលត់សិទ្ធិណាមួយ។

### ២.១.២.២. សិទ្ធិលើបំណុល

តាមន័យធម្មតា គឺជាសិទ្ធិដែលអាចទាមទារផលប្រយោជន៍ពីបុគ្គលណាម្នាក់។

យោងតាមក្រមរដ្ឋប្បវេណី សិទ្ធិលើបំណុលគឺជា សិទ្ធិទាមទារចំពោះមនុស្សឱ្យធ្វើសកម្មភាពជាកំណត់មួយ[19]។

តាមច្បាប់ស្ដីពីក្ស័យធនបានឱ្យនិយមន័យសិទ្ធិលើបំណុល សំដៅដល់សិទ្ធិទទួលការទូទាត់សងពីកូនបំណុល ឬការទូទាត់ពីទ្រព្យសកម្មរបស់កូនបំណុលដែលកើតមានឡើងមុនពេលបើកសំណុំរឿងក្ស័យធន ដោយមិនគិតថាសិទ្ធិលើបំណុលនោះមានលក្ខខណ្ឌមិនទាន់ទូទាត់បាន ឬមានភាពបន្ទាន់ឡើយ លើកលែងតែច្បាប់ចែងច្បាស់ថាជាសិទ្ធិលើបំណុលខាងរដ្ឋបាល[20]។

យោងតាមន័យនៃពាក្យខាងលើយើងអាចស្វែងយល់ន័យនៃពាក្យ "អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល" ខាងលើបានថា អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរំលត់សិទ្ធិលើបំណុល ដោយផ្អែកលើការណ៍ដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិក្នុងអំឡុងពេលដែលច្បាប់បានកំណត់[21]។

## ២.១.៣. ខនពាក់ព័ន្ធ

[18] មាត្រា ៩២៨ នៃក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០

[19] មាត្រា៣៨៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[20] មាត្រា ៤ ចំណុចទី ២ នៃច្បាប់ស្ដីពីក្ស័យធន

[21] មាត្រា ៤៨០ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ជនពាក់ព័ន្ធសំដៅលើជនទាំងឡាយណាដែលអាចធ្វើសកម្មភាពនៅក្នុងរឿងអាជ្ញាយុកាល រួមទាំងសកម្មភាពនៃការបង្អង់ ការផ្អាក ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល និងការបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលផងដែរ។ ជនទាំងនោះរួមមានដូចខាងក្រោមៈ

**២.១.៣.១. ម្ចាស់បំណុល**

ម្ចាស់បំណុល គឺជាជនដែលមានសិទ្ធិទាមទារចំពោះនរណាម្នាក់ឱ្យធ្វើសកម្មភាពកំណត់មួយ [22] ។ ម្ចាស់បំណុលជាជនដែលមានផលប្រយោជន៍ពាក់ពន្ធ័នឹងរឿងអាជ្ញាយុកាល ពីព្រោះប្រសិនបើម្ចាស់បំណុលមិនធ្វើការអនុវត្តសិទ្ធិរបស់ខ្លួនក្នុងអំឡុងពេលដែលច្បាប់កំណត់នេះនឹងឱ្យខ្លួនបាត់សិទ្ធិ។ ម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនក្នុងអំឡុងពេល ៥ ឆ្នាំ គិតចាប់ពីពេលដែលខ្លួនអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបាន។ ហើយពេលនៃការចាប់ផ្ដើមនេះអាស្រ័យទៅតាមកិច្ចសន្យាដែលបានកំណត់។

**២.១.៣.២. កូនបំណុល ឬកូនបំណុលដោយសាមគ្គី**

កូនបំណុល គឺជាជនដែលត្រូវមានកាតព្វកិច្ចធ្វើសកម្មភាពដើម្បីជាផលប្រយោជន៍ដល់ម្ចាស់បំណុល។ ចំណែកឯកូនបំណុលដោយសាមគ្គីមានន័យថាមានបុគ្គលច្រើននាក់ទទួលបន្ទុកនូវកាតព្វកិច្ចសាមគ្គី ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលណាម្នាក់អនុវត្តកាតព្វកិច្ចទាំងអស់ ឬមួយភាគ ឬឱ្យកូនបំណុលទាំងអស់អនុវត្តកាតព្វកិច្ចទាំអស់ ឬមួយភាគីដោយព្រមគ្នា ឬបន្តបន្ទាប់[23] ។ កូនបំណុល និង កូនបំណុលដោយសាមគ្គី គឺជាជនដែលសំខាន់បំផុតពាក់ព័ន្ធរឿងអាជ្ញាយុកាល ដោយសារតែអ្នកទាំងនេះជាជនដែលមានកាតព្វកិច្ចចម្បង ប្រសិបើកាតព្វកិច្ចចម្បងរំលត់ នោះកាតព្វកិច្ចបន្ទាប់បន្សំក៏រលត់ដែរ។

**២.១.៣.៣. អ្នកធានា**

អ្នកធានា គឺជាបុគ្គលដែលបានសន្យាជាមួយម្ចាស់បំណុលថាខ្លួននឹងអនុវត្តកាតព្វកិច្ចមួយផ្នែក ទាំងមូលជាមួយនឹងកូនបំណុលដែលមានកាតព្វកិច្ចចម្បង នៅក្នុងករណីដែលកូនបំណុលមានកាតព្វកិច្ចចម្បងនោះ ពុំអនុវត្តកាតព្វកិច្ចរបស់ខ្លួន ហើយម្ចាស់បំណុលបានយល់ព្រមអំពីការ

[22] មាត្រា ៣៨៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
[23] មាត្រា ៩២១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

សន្យានោះ[24]។ ប្រសិនបើកូនបំណុលដែលមានកាតព្វកិច្ចចម្បងក្លាយជាអសាធនីយ៍ ឬមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន នោះម្ចាស់បំណុលសង្ឃឹមថាខ្លួននឹងមានកូនបំណុលដទៃទៀតមកជំនួស។

### ២.១.៣.៤. អ្នកធានាដោយវត្ថុ

អ្នកធានាដោយវត្ថុ សំដៅដល់បុគ្គលដែលបង្កើតសិទ្ធិប្រាតិភោគប្រត្យក្សលើទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីធានាកាតព្វកិច្ចរបស់អ្នកដទៃ[25]។ មានន័យថាបុគ្គលនោះបានយកទ្រព្យសម្បត្តិរបស់ខ្លួនទៅធានាកាតព្វកិច្ចឱ្យអ្នកដទៃ។

ឧទាហរណ៍: លោក ក បានយកដីរបស់ខ្លួនដើម្បីធានាកាតព្វកិច្ចរបស់លោក ខ ដែលខ្ចីលុយចំនួន ៥០០០ដុល្លា ពីលោក គ។ ដូច្នេះលោក ក ជាអ្នកធានាដោយវត្ថុ។

### ២.១.៣.៥. តតិយជនដែលបានធ្វើលទ្ធកម្ម

តតិយជនដែលបានធ្វើលទ្ធកម្ម សំដៅលើបុគ្គលដែលដែលបានធ្វើលទ្ធកម្មនូវវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគប្រត្យក្សដែលបង្កើតឡើងដោយកូនបំណុល ឬអ្នកធានា ដើម្បីធានាកាតព្វកិច្ចរបស់ខ្លួន [26] ។ មានន័យថាកូនបំណុល ឬអ្នកធានាបានយកទ្រព្យសម្បត្តិរបស់ខ្លួនដាក់ធានាកាតព្វកិច្ច ប៉ុន្តែមានតតិយជនបានធ្វើលទ្ធកម្មនូទ្រព្យសម្បត្តិនោះ ដូច្នេះតតិយជននោះ ត្រូវបានហៅថាជា តតិយជនដែលបានធ្វើលទ្ធកម្ម។

ឧទាហរណ៍: លោក ក បានបង្កើតហ៊ីប៉ូតែកនៅលើដី (១) មួយកន្លែងឱ្យ លោក ខ ដែលជាម្ចាស់បំណុលហ៊ីប៉ូតែក។ ស្របពេលនោះ លោក គ បានកាន់កាប់ដីនោះស្របតាមបញ្ញត្តមាត្រា ១៦២នៃក្រមរដ្ឋប្បវេណី។ ដូច្នេះលោក គ ជាតតិយជនដែលបានធ្វើលទ្ធកម្ម មានសិទ្ធិលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។

### ២.១.៣.៦. សន្តតិជន

សន្តតិជន គឺជាជនដែលទទួលបន្តនូវសិទ្ធិ និងករណីកិច្ចរបស់មតកជនតាមសន្តតិកម្ម។

---

[24] មាត្រា ៩០០ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[25] មាត្រា ៧៦៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[26] មាត្រា ៧៦៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

នៅក្នុងរឿងសន្តតិកម្ម ប្រសិនបើមានម្ចាស់បំណុលបានដាក់ពាក្យទាមទារសិទ្ធិលើបំណុលសន្តតិជនជា ជនពាក់ព័ន្ធដែលអាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ក្នុងករណីប្រសិនបើកូនបំណុលដែលជាមតកជន បានទទួលមរណភាព ហើយម្ចាស់បំណុលបានប្តឹងទាមទារឱ្យសន្តតិជនអនុវត្តកាតព្វកិច្ច តែសិទ្ធិលើបំណុលនោះបានហួសអំឡុងពេល៥ ឆ្នាំ។ ដូច្នេះសន្តតិជន មានសិទ្ធិលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបាន។

## ២.១.៤. វិសាលភាពនៃការលើកឡើង និងការបោះបង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

### ២.១.៤.១. វិសាលភាពនៃការលើកឡើង

ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយកូនបំណុលមានអានុភាពដាច់ខាត ចំណែកឯការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយជនក្រៅពីកូនបំណុលមានអានុភាពមិនដាច់ខាត។ នៅក្នុងការលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលគឺជាស្វ័យឆន្ទៈរបស់ភាគី ហើយតុលាការត្រូវប្រកាន់យកគោលការណ៍តុលាការអកម្ម។ខាងក្រោមនេះជាការបកស្រាយពីគោលការណ៍ថៅក្រមអកម្ម និងការលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។

#### ២.១.៤.១.១. គោលការណ៍ចៅក្រមអកម្ម

ជាគោលការណ៍ តុលាការមិនអាចសម្រេចសេចក្តីដោយយកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលភាគីមិនបានលើកឡើង ដោយឯកឯងបាននោះទេ[27]។ នៅក្នុងនីតិវិធីនេះតុលាការគឺជាតុលាការអកម្ម។ តុលាការអកម្ម សំដៅទៅលើតុលាការដែលមិនអាចធ្វើសកម្មភាពក្នុងការស្វែងរកនូវអ្វីៗ ដែលភាគីមិនបានបង្ហាញនោះឡើយ មានន័យថាតុលាការត្រូវចេញសាលក្រមចំពោះការទាមទារទាំងអស់ដែលភាគីបានសុំ ហើយតុលាការមិនអាចចេញសាលក្រមចំពោះចំណុចណាដែលភាគីមិនបានសុំនោះឡើយ[28]។ ពោលគឺតុលាការអាចទទួលយកមកធ្វើជាមូលដ្ឋាននៃការសម្រេចសេចក្តីផ្អែកលើអង្គហេតុដែលភាគីបានអះអាង និងទទួលយកមកពិនិត្យតែភស្តុតាងទាំងឡាយណាដែលភាគីស្នើរសុំឱ្យពិនិត្យតែប៉ុណ្ណោះ។

[27] មាត្រា ៤៨៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[28] មាត្រា ១៨២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

នីតិវិធីរដ្ឋប្បវេណី អាចដំណើរការទៅបានដោយការដាក់ពាក្យបណ្តឹងរបស់ដើមចោទទាមទារ និងហេតុការណ៍ដែលភាគីបានអះអាង ដើម្បីបញ្ជាក់ការទាមទារ រួមទាំងភស្តុតាងនានាដែលភាគីបានស្នើរសុំឱ្យពិនិត្យ ពោលគឺសិទ្ធិស្វ័យសម្រេចរបស់បុគ្គលត្រូវតែគោរព។ ដូចនេះនៅពេលដែលតុលាការបានព្យាយាមស្វែងរកអង្គហេតុ ឬស្វែងរកភស្តុតាងផ្សេងៗដើម្បីយកមកពិនិត្យដើម្បីឈានដល់ការសម្រេចសេចក្តី គឺជាការបំពានលើគោលការណ៍នៃសិទ្ធិចាត់ចែង ពោលគឺស្វ័យភាពឆន្ទៈរបស់ភាគី។ ដោយគោរពនូវគោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី ក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ឆន្ទានុសិទ្ធិរបស់តុលាការត្រឹមតែការដឹកនាំនីតិវិធីតែប៉ុណ្ណោះ ដោយឡែកការចាត់ចែងនូវសកម្មភាពនៃបណ្តឹងគឺជាសិទ្ធិរបស់ភាគី[29]។

**២.១.៤.១.២. វិសាលនៃការលើកឡើងនូវអាជ្ញាយុកាលដោយកូនបំណុល**

ជាគោលការណ៍ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលបានលើកឡើងដោយកូនបំណុលមានវិសាលភាពជាផលប្រយោជន៍ទៅដល់ជនផ្សេងទៀត ដែលមានផលប្រយោជន៍ពាក់ព័ន្ធ ដូចជាកូនបំណុលដោយសាមគ្គី អ្នកធានាដោយវត្ថុ និងតតិយជនដែលបានធ្វើលទ្ធកម្ម មានន័យថាកាតព្វកិច្ចរវាងកូនបំណុល និងជនផ្សេងទៀតដូចជា កូនបំណុលដោយសាមគ្គីផ្សេងទៀត អ្នកធានាដោយវត្ថុចំពោះម្ចាស់បំណុល ត្រូវរលត់[30]។ ការបញ្ញត្តបែបនេះ គឺដើម្បីបញ្ចៀសនូវគំនិតទុច្ចរិតដែលធ្វើឡើងដោយកូនបំណុល និងម្ចាស់បំណុលដើម្បីកេងយកផលប្រយោជន៍ពី កូនបំណុលដោយសាមគ្គីផ្សេងទៀត អ្នកធានា អ្នកធានាដោយវត្ថុ ឬតតិយជនផ្សេងទៀត។ ប្រសិនបើក្រមរដ្ឋប្បវេណីមិនបញ្ញត្តដូច្នេះទេ នៅពេលដែលម្ចាស់បំណុលបានធ្វើការទាមទារតាមផ្លូវតុលាការ កូនបំណុលអាចឆ្លៀតឱកាស ឃុបឃិតជាមួយម្ចាស់បំណុលដោយលើកតែអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរបស់ខ្លួន ហើយម្ចាស់បំណុលនៅតែអាចទាមទារឱ្យបុគ្គលផ្សេងទៀតអនុវត្តកាតព្វកិច្ចដដែលនោះទៅវិញ វាមិនមែនជាការត្រឹមត្រូវនោះទេ។ ស្របតាមគោលការណ៍ខាងលើប្រសិនបើកាតព្វកិច្ចចម្បងត្រូវបានរលត់ នោះកាតព្វកិច្ចបន្ទាប់បន្សំក៏ត្រូវបានរលត់ដែរ។ វាគ្មានន័យអ្វីដែលត្រូវឱ្យបុគ្គលដទៃមកអនុវត្តកាតព្វកិច្ចមួយដែលបានរលត់ហើយនោះទេ។ ប្រសិនបើកូនបំណុលបានលើកឡើងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរួចរាល់ហើយ តែបែរជានៅតែ

[29] នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានប្រកាន់យកគោលការណ៍ថៅក្រមអកម្មដោយមិនឱ្យតុលាការធ្វើការសម្រេចសេចក្តីយកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលភាគីមិនបានលើកឡើងទេ វាខុសគ្នាពីក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាដែលតុលាការត្រូវតែលើកឡើងនូវអាជ្ញយុកាលនៃការរំលត់សិទ្ធិបំណុល ទោះបីជាភាគីមិនបានលើកឡើងក៏ដោយ។

[30] មាត្រា ៤៨៦ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ឱ្យអ្នកធានា អ្នកធានាដោយវត្ថុនៅតែអនុវត្តកាតព្វកិច្ចនោះដដែល វាហាក់បីដូចជាអយុត្តិធម៌ចំពោះអ្នកទាំងនោះខ្លាំងណាស់ ព្រោះថាទំនាក់ទំនងដែលអ្នកនោះបានបង្កើតឡើងជាមួយម្ចាស់បំណុលគឺសុទ្ធតែដើម្បីផលប្រយោជន៍កូនបំណុលតែប៉ុណ្ណោះ។

ឧទាហរណ៍: លោក ក បានឱ្យលុយលោក ខ ខ្ចីចំនួន ៥០០០ដុល្លារ នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៩ ហើយលោក ខ សន្យាថានឹងសងវិញនៅថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១០ ដោយមានលោក គ ជាអ្នកធានា។ ក៏ប៉ុន្តែលោក ខ មិនបានសងតាមការកំណត់ហើយនៅថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៦ លោក ក បានដាក់ពាក្យប្តឹង។

ក្នុងករណីនេះ ប្រសិនបើលោក ខ បានលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិបំណុល នោះលោក គ ដែលជាអ្នកធានាក៏អាចរួចផុតពីការអនុវត្តកាតព្វកិច្ចបានដែរ។

### ២.១.៤.១.៣. វិសាលភាពនៃការលើកឡើងអាជ្ញាយុកាលដោយជនក្រៅពីកូនបំណុល

ជាគោលការណ៍ ជនទាំងឡាយណាដែលមានផលប្រយោជន៍ ជននោះសុទ្ធតែអាចចាត់ចែងនូវផលប្រយោជន៍របស់ខ្លួនដោយសេរី ស្របតាមគោលការណ៍នេះ អ្នកធានា អ្នកធានាដោយវត្ថុ និងតតិយជនដែលបានធ្វើលទ្ធកម្ម សុទ្ធតែមានផលប្រយោជន៍នៅក្នុងរឿងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដូច្នេះជនទាំងនោះមានសេរីភាពពេញលេញក្នុងការលើកឡើង ឬមិនលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ក៏ប៉ុន្តែ វិសាលភាពនៃការលើកឡើងរបស់ជនក្រៅពីកូនបំណុល ដែលបានលើកឡើងពីអាជ្ញាយុកាលនោះ វាមានវិសាលភាពខុសគ្នាពីការលើកឡើងដោយកូនបំណុល។ បានសេចក្តីថា ប្រសិនបើ អ្នកធានា អ្នកធានាដោយវត្ថុ តតិយជនដែលបានធ្វើលទ្ធកម្ម ឬតតិយជនដែលបានទទួលផលប្រយោជន៍នៃអាជ្ញាយុកាលនេះបានលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សិទ្ធិលើបំណុលនោះរលត់តែរវាងជនទាំងនោះជាមួយនឹងម្ចាស់បំណុលតែប៉ុណ្ណោះ[31]។ ហើយម្ចាស់បំណុលនៅតែមានសិទ្ធិលើបំណុលលើកូនបំណុលរបស់ខ្លួនដដែល ពោលគឺ ម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច តែមិនអាចទាមទារឱ្យជនផ្សេងទៀតក្រៅពីកូនបំណុលអនុវត្តកាតព្វកិច្ចបានឡើយ។

ការណ៍ដែលក្រមរដ្ឋប្បវេណីបញ្ញត្តដូច្នេះ គឺដើម្បីតែការពារផលប្រយោជន៍របស់ជនក្រៅពីកូនបំណុលដូចជា អ្នកធានា អ្នកធានាដោយវត្ថុ និងតតិយជនដែលមានផលប្រយោជន៍ និងដើម្បីបញ្ចៀសនូវគំនិតទុច្ចរិតរបស់កូនបំណុល ប្រសិនបើកូនបំណុលមិនលើកឡើងពីអាជ្ញាយុកាលទេ

[31] មាត្រា ៤៨៦ កថាខណ្ឌទី២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

នោះ កាតព្វកិច្ចរបស់គាត់នៅតែមានដដែល មិនប៉ះពាល់អ្វីដល់បុគ្គលដទៃដែលបានលើកឡើងទេ។

ឧទាហរណ៍: ម្ចាស់បំណុលបានប្តឹងទាមទារឱ្យអ្នកធានាអនុវត្តកាតព្វកិច្ចជំនួសកូនបំណុល ក៏ប៉ុន្តែសិទ្ធិលើបំណុលនោះហួសអាជ្ញាយុកាល ហើយអ្នកធានាបានលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនៅចំពោះមុខតុលាការ នាំឱ្យសិទ្ធិលើបំណុលចំពោះអ្នកធានាត្រូវបានរលត់។ ក៏ប៉ុន្តែម្ចាស់បំណុលនៅតែមានសិទ្ធិលើបំណុលចំពោះកូនបំណុលដដែល។

### ២.១.៤.២. វិសាលភាពនៃការបោះបង់ផលប្រយោជន៍នៃអាជ្ញាយុកាល

ការបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលអាចធ្វើឡើងដោយកូនបំណុល និងជនក្រៅពីកូនបំណុលផ្សេងទៀតដែលមានប្រយោជន៍ ប៉ុន្តែអានុភាពនៃការបោះបង់ចោលនេះមានលក្ខណៈខុសគ្នាដូចខាងក្រោម៖

### ២.១.៤.២.១. ការបោះបង់ផលប្រយោជន៍នៃអាជ្ញាយុកាលដោយកូនបំណុល

ចំពោះការបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានភាពខុសគ្នាពីការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានន័យថាការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយកូនបំណុលមានអានុភាពដាច់ខាត ចំណែកឯការបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលមានអានុភាពមិនដាច់ខាត រួមទាំងការបោះបង់ចោលផលប្រយោជន៍អាជ្ញាយុកាលដោយសាមីខ្លួនផ្ទាល់ និងការបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលដោយតតិយជន។ អ្វីដែលខុសប្លែកគ្នានោះ នៅត្រង់ថាការបោះបង់ចោលផលប្រយោជន៍អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលបានធ្វើឡើង ដោយកូនបំណុលមានអានុភាពតែចំពោះកូនបំណុល និងម្ចាស់បំណុលតែប៉ុណ្ណោះ។ បានសេចក្តីថា បើកូនបំណុលយល់ព្រមអនុវត្តកាតព្វកិច្ច ទោះបីជាហួសអំឡុងពេលដែលច្បាប់កំណត់ក៏ដោយ ក៏ការយល់ព្រមនោះ មិនចងកាតព្វកិច្ចឱ្យតតិយជនដែលមានប្រយោជន៍ផ្សេងទៀតអនុវត្តកាតព្វកិច្ចតាមខ្លួននោះដែរ។

ត្រង់ចំណុចនេះ ដោយសារតែក្រមរដ្ឋប្បវេណីចង់ការពារផលប្រយោជន៍របស់តតិយជនពីគំនិតទុច្ចរិតរបស់ ម្ចាស់បំណុល និងកូនបំណុលដែលត្រូវរូវគ្នា បោះបង់ផលប្រយោជន៍អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ហើយកូនបំណុលយកលេសថាខ្លួនអលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ចដោយយកអ្នកធានា ឬអ្នកធានាដោយវត្ថុ កូនបំណុលដោយសាមគ្គី មកអនុវត្តកាតព្វកិច្ច

ជំនួសខ្លួនទៅវិញ។ ប្រសិនបើរដ្ឋប្បវេណីមិនចែងដូច្នេះ ហាក់បីដូចជាអយុត្តិធម៌ចំពោះអ្នកធានា អ្នកធានាដោយវត្ថុ កូនបំណុលដោយសាមគ្គី និងជនដែលមានផលប្រយោជន៍ផ្សេងទៀត ដែលខ្លួនមិនបានទទួលផលប្រយោជន៍ពីសិទ្ធិលើបំណុលនោះសោះ តែបែរជាត្រូវទទួលបន្ទុកអនុវត្តកាតព្វកិច្ចជំនួសកូនបំណុលទៅវិញ។

ឧទាហរណ៍: លោក ក ដែលកូនបំណុលបានបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល(យល់ព្រមអនុវត្តកាតព្វកិច្ច) ដូច្នេះលោក ខ ដែលជាអ្នកធានា ក៏នៅតែអាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដដែល។

**២.១.៤.២.២. ការបោះបង់ផលប្រយោជន៍នៃអាជ្ញាយុកាលដោយជនក្រៅពីកូនបំណុល**

ផ្ទុយពីការបោះបង់ចោលផលប្រយោជន៍អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលធ្វើឡើងដោយកូនបំណុល តតិយជនដែលមានផលប្រយោជន៍ផ្សេងទៀតនៅក្នុងរឿងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដូចជា អ្នកធានា អ្នកធានាដោយវត្ថុ កូនបំណុលដោយសាមគ្គី និងតតិយជនដែលបានធ្វើលទ្ធកម្ម មានសិទ្ធិក្នុងការបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដូចកូនបំណុលដែរ។ ក៏ប៉ុន្តែអានុភាពនេះ មានត្រឹមតែរវាងម្ចាស់បំណុល និងជនខាងលើនេះ។ មានន័យថាប្រសិនបើជនទាំងនេះ គាត់មានឆន្ទៈចង់អនុវត្តកាតព្វកិច្ចវាជាសេរីភាពខាងឆន្ទៈរបស់គាត់ ប៉ុន្តែសេរីភាពនេះ វាមិនប៉ះពាល់ដល់កូនបំណុលដែលមានបំណងចង់លើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ ពោលគឺជនក្រៅពីកូនបំណុលអាចបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ទន្ទឹមជាមួយនឹងពេលដែលកូនបំណុលលើកឡើងពីអាជ្ញាយុកាលការរំលត់សិទ្ធិលើបំណុល។

ក៏ប៉ុន្តែ នៅក្នុងសង្គមយើងបច្ចុប្បន្នប្រហែលជាគ្មានបុគ្គលណាម្នាក់ចង់អនុវត្តកាតព្វកិច្ចរបស់ខ្លួន ស្របពេលដែលខ្លួនមានសិទ្ធិមិនអនុវត្តកាតព្វកិច្ចនោះឡើយ។ ដូច្នេះប្រហែលជាអាចសន្និដ្ឋានបានថា ទាំងកូនបំណុល និងតតិយជនផ្សេងទៀត សុទ្ធតែចង់លើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិសិទ្ធិលើបំណុល។

ទោះបីជាយ៉ាងណាក៏ដោយ បញ្ញត្តិស្តីពីការបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺជាបញ្ញត្តិដែលអនុវត្តដោយបង្ខំ មានន័យថាក្រមរដ្ឋប្បវេណីបានហាមឃាត់ មិនឱ្យកូនបំណុលធ្វើការបោះបង់ផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមុនពេលអាជ្ញាយុកាលនោះបានសម្រេចទេ ពោលគឺមិនឱ្យមានការធ្វើកិច្ចសន្យាពិសេស

រវាងម្ចាស់បំណុល និងកូនបំណុលថាកូនបំណុលយល់ព្រមបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដើម្បីជាថ្នូរនឹងការអនុវត្តកាតព្វកិច្ចរបស់ម្ចាស់បំណុលនោះទេ[32]។

ឧទាហរណ៍: កូនបំណុល ក ដើម្បីតែទទួលបានលុយពីម្ចាស់បំណុលបន្ថែមសុខចិត្តធ្វើកិច្ចសន្យាពិសេសមួយទៀតថាខ្លួននឹងមិនលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ។

## ២.១.៥. ប្រភេទនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវបានបែងចែកជា ៣ ប្រភេទ ដោយផ្អែកលើអំឡុងពេល និងលក្ខខណ្ឌនីមួយៗ។

### ២.១.៥.១. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ មានអំឡុងពេល ៥ឆ្នាំ ដើម្បីអនុវត្តបញ្ញត្តិនេះបាន គេត្រូវពិនិត្យមើលពីលក្ខណៈសម្បត្តិរបស់ម្ចាស់បំណុល និងកូនបំណុល ព្រមទាំងទំនាក់ទំនងរដ្ឋប្បវេណីកិច្ច[33]។ ជាទូទៅគ្រប់សិទ្ធិលើបំណុលទាំងអស់សុទ្ធតែមានអំឡុងពេល ៥ឆ្នាំ ដែលគិតចាប់ពីពេលដែលម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបាន លើកលែងតែសិទ្ធិលើបំណុលខ្លះមានបទបញ្ញត្តិ ឬច្បាប់ ឬបទដ្ឋានគតិយុត្តិផ្សេងកំណត់ពី អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ។

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ ដែលមានម្ចាស់បំណុល និងកូនបំណុលសុទ្ធតែជារដ្ឋប្បវេណីករ ហើយវាមិនពាក់ព័ន្ធទៅនឹងពាណិជ្ជកិច្ចបន្ទាប់បន្សំ។ ប៉ុន្តែក្នុងករណីដែលច្បាប់ពាណិជ្ជកម្មមិនបានកំណត់ពីអំឡុងពេលនៃអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលក្នុងរឿងពាណិជ្ជកម្មទេ គេអាចយកបញ្ញត្តិនៃអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលទូទៅ យកមកអនុវត្តបានដែរ ពីព្រោះថាអាជ្ញាយុកាលនេះគឺជាវិធានទូទៅដែលគេត្រូវយកមកអនុវត្តនៅពេលដែលគ្មានវិធាននៃបញ្ញត្តិពិសេស។

[32] ជាទូទៅប្រសិនបើកិច្ចសន្យាមួយដែលផ្ទុយនឹងបញ្ញាត្តដែលអនុវត្តកិច្ចសន្យានោះនឹងត្រូវទុកជាមោឃៈ។ បញ្ញាត្តស្តីពីការហាមឃាត់មិនឱ្យបោះបង់ចោលផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិបំណុលជាបញ្ញាត្តដែលអនុវត្តដោយបង្ខំ។ ប្រសិនបើកិច្ចសន្យាដែលផ្ទុយនឹងបញ្ញាត្តនេះនឹងត្រូវទុកជាមោឃៈ។

[33] មាត្រា ៤៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅគេគិតចាប់ពីពេលដែលម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនដោយមិនទាក់ទងទៅនឹងការគិតចាប់ផ្តើម អំឡុងពេលសាជាថ្មីដោយសារការផ្អាកការទាមទារតាមផ្លូវតុលាការ។

### ២.១.៥.២. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមានអំឡុងពេលខ្លី

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមានអំឡុងពេលខ្លី វាខុសប្លែកគ្នាពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ ដោយហេតុថាអាជ្ញាយុកាលនេះមានភាគីម្ខាងជាពាណិជ្ជករ ហើយភាគីម្ខាងទៀតជារដ្ឋប្បវេណីករ ពោលគឺម្ចាស់បំណុលជាពាណិជ្ជករ ឬផលិតករ ហើយកូនបំណុលជារដ្ឋប្បវេណីក[34]រ។ ដូច្នេះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះ មានអំឡុងពេលតែ ២ឆ្នាំ ប៉ុណ្ណោះ។ ការកំណត់យកអំឡុងពេល ២ឆ្នាំ នេះដោយសារតែនីតិករខ្មែរគិតថានៅក្នុងប្រតិបត្តិការរបស់អ្នកប្រើប្រាស់មានការពិបាកនឹងរក ព្រមទាំងរក្សាទុកនូវភស្តុតាងនៃការសង។ ម៉្យាងទៀតនៅក្នុងទំនាក់ទំនងរវាងពាណិជ្ជករ ឬផលិតករជាមួយជនដែលមិនមែនជាពាណិជ្ជករ ឬផលិតករ ឃើញថា ពាណិជ្ជករ ឬផលិតករ ជាជនដែលមានការយល់ដឹងខ្ពស់អំពីសិទ្ធិរបស់ខ្លួន ដូច្នេះអំឡុងពេល ២ឆ្នាំ នេះវាគ្រប់គ្រាន់សម្រាប់ឱ្យគាត់អនុវត្តសិទ្ធិរបស់ខ្លួនហើយ។

ឧទាហរណ៍: ពាណិជ្ជករ បានលក់ផលិតផលរបស់ខ្លួនទៅឱ្យជនដែលមិនមែនជាពាណិជ្ជករ ឬផលិតករ ដូច្នេះ ពាណិជ្ជករ ឬផលិតករនោះអាចទាមទាឱ្យជនដែលមិនមែនជាពាណិជ្ជករ ឬផលិតករ សងប្រាក់ពីការលក់ផលិតផលនោះក្នុងអំឡុងពេល ២ឆ្នាំ។

### ២.១.៥.៣. អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរមានអំឡុងពេល ៥ឆ្នាំ ដែលមានម្ចាស់បំណុល និងកូនបំណុលមានលក្ខណៈសម្បត្តិ ព្រមទាំងមានការផ្អាក និងការបង្អង់ដូចអាជ្ញាយុកាលនៃការរំលត់លើបំណុលទូទៅដែរ។ ក៏ប៉ុន្តែ អំឡុងពេលនៃអាជ្ញាយុកាលនេះត្រូវបានគិតចាប់ផ្តើមខុសពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ ពោលគឺ ពេលវេលានៃការចាប់ផ្តើមគិតចាប់ពីពេលដែលសាលក្រម ឬសាលដីកាចូលជាស្ថាពរ ឬការផ្សះផ្សា ការលះបង់ការទាមទារ ឬការទទួលស្គាល់ការទាមទារតាមផ្លូវតុលាការ[35]។ លើសពីនេះទៅទៀត ចំពោះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមានអំឡុងពេលខ្លី ដែលត្រូវបានផ្អាក ដោយសារការ

[34] មាត្រា ៤៨៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[35] មាត្រា ៤៨៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ទាមទារតាមផ្លូវតុលាការ ការទទួលស្គាល់ការទាមទារ ឬការផ្សះផ្សា តាមផ្លូវតុលាការ ក៏អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលខ្លីនេះ មានអំឡុងពេល ៥ឆ្នាំ(មិនមែន ២ឆ្នាំទេ) ដែរ។ ផ្ទុយទៅវិញ ទោះបីជាសិទ្ធិលើបំណុលនោះបានចូលជាស្ថាពរ ដោយសាលក្រម ឬសាលដីកា ការផ្សះផ្សាដែលតាមផ្លូវតុលាការ ការទទួលស្គាល់ការទាមទារក៏ដោយ ប្រសិនបើពេលកំណត់ដែលត្រូវអនុវត្តកាតព្វកិច្ចមិនទាន់បានមកដល់មុនពេលសិទ្ធិលើបំណុលបានចូលជាស្ថាពរគឺអំឡុងពេល ៥ ឆ្នាំនោះគិតចាប់ពីពេលដែលពេលកំណត់អនុវត្តកាតព្វកិច្ចបានមកដល់។

ឧទាហរណ៍: ម្ចាស់បំណុលបានប្ដឹងទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច ហើយសាលក្រមបានចូលជាស្ថាពរនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ ដូចនេះអាជ្ញាយុកាលត្រូវគិតចាប់ពីពេលដែលសាលក្រមនោះបានចូលជាស្ថាពរ។

## ២.២. ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ដើម្បីឱ្យអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានសម្រេចចំពោះកូនបំណុលត្រូវបំពេញលក្ខខណ្ឌមួយចំនួនដែលបានកំណត់ដូចខាងក្រោម៖

### ២.២.១. លក្ខខណ្ឌ

#### ២.២.១.១. អំឡុងពេលអាជ្ញាយុកាល

#### ២.២.១.១.១. ពេលចាប់ផ្ដើម

អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវគិតចាប់ផ្ដើមពីពេលដែលម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបាន[36]។ ពេលចាប់ផ្ដើមនេះអាចប្រែប្រួលទៅតាមការកំណត់របស់ភាគីនៅក្នុងកិច្ចសន្យានីមួយៗ

**ក. កិច្ចសន្យាដែលមានពេលកំណត់ជាក់លាក់**

ប្រសិនបើ នៅក្នុងកិច្ចសន្យាមួយគូភាគីបានកំណត់យកពេលកំណត់ជាក់លាក់ណាមួយដើម្បីអនុវត្តកាតព្វកិច្ច ពេលកំណត់នោះ គឺជាពេលចាប់ផ្ដើមគិតអំឡុងពេលអាជ្ញាយុកាល ហើយកូនបំណុលត្រូវអនុវត្តកាតព្វកិច្ចចាប់ពីពេលនោះ។ ចំណែកឯ ម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនចាប់ពីពេលនោះដែរ ពោលគឺការទាមទាររបស់ម្ចាស់បំណុលឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច។

[36] មាត្រា ៤៨១ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ឧទាហរណ៍: នៅក្នុងករណីដែលភាគីទាំងសងខាងបានព្រមព្រៀងគ្នា នៅពេលដែលអនុវត្តកាតព្វកិច្ច ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០១ ដូច្នេះកាលបរិច្ឆេទនេះ គឺជាកាលបរិច្ឆេទពិតប្រាកដដែលត្រូវបានកំណត់។ កូនបំណុលត្រូវអនុវត្តកាតព្វកិច្ច ហើយម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច។

**ខ. កិច្ចសន្យាដែលមានពេលកំណត់មិនពិតប្រាកដ**

កិច្ចសន្យាដែលមានពេលកំណត់មិនពិតប្រាកដ គឺជាការព្រមព្រៀងដែលបានធ្វើឡើងរវាងម្ចាស់បំណុល និងកូនបំណុលដោយមិនយកពេលកំណត់ជាក់លាក់ណាមួយសម្រាប់អនុវត្តកាតព្វកិច្ច។ ក៏ប៉ុន្តែកិច្ចសន្យានេះ នឹងត្រូវអនុវត្តកាតព្វកិច្ចនូវពេលដែលម្ចាស់បំណុលបានទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច ហើយពេលវេលានៃការទាមទារនោះ គឺជាពេលចាប់ផ្តើមនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។

ឧទាហរណ៍: កិច្ចសន្យាខ្ចីបរិភោគរវាងម្ចាស់បំណុល និងកូនបំណុលដោយមិនបានកំណត់អំពីពេលសងរបស់កូនបំណុល ដែលបានធ្វើឡើងនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១៦។ ដូច្នេះប្រសិនបើម្ចាស់បំណុលបានទាមទារឱ្យកូនបំណុលសងប្រាក់មកខ្លួនវិញ ពេលវេលានៃការទាមទារនោះគឺជាពេលចាប់ផ្តើមគិតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។

**គ. កិច្ចសន្យាដែលមានលក្ខខណ្ឌបង្អង់**

ប្រសិនបើកិច្ចសន្យាមួយត្រូវបានបង្កើតឡើងដោយភ្ជាប់ជាមួយលក្ខខណ្ឌបង្អង់លើកាតព្វកិច្ច ឬសិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ឬ សកម្មភាពឯកតោភាគីអានុភាពនៃកាតព្វកិច្ច ឬសិទ្ធិលើបំណុលត្រូវកើតឡើងចាប់តាំងពីពេលដែលលក្ខខណ្ឌបង្អង់បានមកដល់[37]។ ពេលចាប់ ផ្តើមគិតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ក៏គិតចាប់ពីពេលដែលលក្ខខណ្ឌនៃការបង្អង់នោះបានមកដល់។ បានន័យថាកូនបំណុលត្រូវអនុវត្តកាតព្វកិច្ច ហើយម្ចាស់បំណុលអាចទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចបាន។

ឧទាហរណ៍: លោក ក បានសន្យាថាប្រសិនបើលោក ខ ប្រលងជាប់ចៅក្រមជំនាន់ទី ៧ នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ លោក ក នឹងទិញឡានម៉ាក កាម៉ារី ឆ្នាំ ២០១២ ឱ្យមួយគ្រឿង។

**២.២.១.១.២. អំឡុងពេល**

[37] មាត្រា ៣២៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ជាគោលការណ៍ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានអំឡុងពេល ៥ឆ្នាំ[38]។ ប៉ុន្តែទាក់ទងនឹងសិទ្ធិលើបំណុល ថ្លៃទិញទំនិញ ឬ សេវា រវាងផលិតករ ឬ ពាណិជ្ជករលក់ទៅឱ្យអ្នកដែលមិនមែនជាពាណិជ្ជករគឺ រយៈពេលនៃអាជ្ញាយុកាលមានត្រឹមតែ ២ឆ្នាំ ទេ ព្រោះសិទ្ធិលើបំណុលចំពោះអ្នកប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការរបស់អ្នកប្រើប្រាស់មានការពិបាកនឹងរក ភស្តុតាងនៃការសង ហេតុនេះហើយទើបក្រមរដ្ឋប្បវេណីបញ្ញត្តអំពីអំឡុងពេលខ្លី[39]។

ឧទាហរណ៍: ក ទិញទំនិញនៅហាងរបស់ គ នៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០១១ អត់បានឱ្យលុយ។ ដូច្នេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិបំណុល គឺមានអំឡុងពេលតែ ២ឆ្នាំ គិតចាប់ពីថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០១១។

ម្យ៉ាងវិញទៀតចំពោះសិទ្ធិលើបំណុល ដែលបានចូលជាស្ថាពរដោយអានុភាពសាលក្រម ឬ សាលដីកា ឬការផ្សះផ្សាតាមផ្លូវតុលាការ ឬ វិធីផ្សេងទៀតដែលមានអានុភាពដូចនឹងសាលក្រមស្ថាពរ អំឡុងពេលនៃអាជ្ញាយុកាលត្រូវមានអំឡុងពេល ៥ ឆ្នាំ គិតចាប់ពីពេលសិទ្ធិលើបំណុលដើមចូលជាស្ថាពរ។ ផ្ទុយមកវិញ បើនៅពេលដែលលិខិតទាំងនោះចូលជាស្ថាពរ មុនពេលកំណត់ត្រូវអនុវត្តមិនទាន់ដល់អំឡុងពេលនៃអាជ្ញាយុកាល គឺមានអំឡុងពេល ៥ ឆ្នាំ ឬ ២ ឆ្នាំ គិតចាប់ពីពេលកំណត់ត្រូវអនុវត្តកាតព្វកិច្ចមកដល់[40]។

[38] មាត្រា ៤៨២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[39] មាត្រា ៤៩៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[40] មាត្រា ៤៨៤ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

### ២.២.១.២. ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ជាគោលការណ៍ទោះបីជាអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលហួសអំឡុងពេល ៥ឆ្នាំក៏ដោយ ប្រសិនបើអ្នកដែលមានសិទ្ធិលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនបានលើកឡើងទេ ត្រូវចាត់ទុកថា សិទ្ធិលើបំណុលនោះ មិនត្រូវបានរលត់ឡើយ។ ដូច្នេះការលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺជាលក្ខខណ្ឌចាំបាច់ដែលត្រូវលើកឡើង ដោយអ្នកដែលមានសិទ្ធិលើកឡើង ហើយតុលាការក៏មិនអាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជំនួសជនទាំងនោះដែរ។

#### ២.២.១.២.១. ភាពចាំបាច់នៃការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

យោងតាមកថាខណ្ឌទី១ មាត្រា៤៨៦ នៃក្រមរដ្ឋប្បវេណី តុលាការមិនអាចលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយខ្លួនឯងបានទេ ទោះបីជាបានដឹងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក៏ដោយ ពីព្រោះបើអនុញ្ញាតឱ្យតុលាការអាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺវានឹងបំពាននូវ គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន។ លើសពីនេះទៅទៀត បញ្ហានៃការលើកឡើងនេះ ជាផលប្រយោជន៍របស់ភាគីទេ។ ដូច្នេះ ការលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលរបស់ភាគីដែលមានប្រយោជន៍នេះ គឺជាភាពចាំបាច់មួយដើម្បីឱ្យតុលាការធ្វើការវិនិច្ឆ័យដើម្បីចេញសាលក្រម ដោយផ្អែកលើអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។

#### ២.២.១.២.២. បុគ្គលដែលអាចលើកឡើងនូវអាជ្ញាយុកាល

ជាគោលការណ៍ បុគ្គលដែលអាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបាន គឺមានតែកូនបំណុល កូនបំណុលដោយសាមគ្គី អ្នកធានាដោយវត្ថុ និងតតិយជនបានធ្វើលទ្ធកម្មទេ ប៉ុន្តែក្នុងក្រមរដ្ឋប្បវេណីកថាខណ្ឌទី ២ នៃមាត្រា ៤៨៦ អនុញ្ញាតឱ្យបុគ្គលដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់ ក៏អាចលើកឡើងពីអាជ្ញាយុកាលបានផងដែរ។ បុគ្គលដែលមានប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់ គឺក្រមមិនបានកំណត់ឱ្យបានច្បាស់លាស់ទេថា តើបុគ្គលប្រភេទណាចាត់ទុកថាជាបុគ្គលដែលមានផលប្រយោជន៍ត្រូវតាមត្រូវតាមផ្លូវច្បាប់? ដូច្នេះអាស្រ័យទៅលើការបកស្រាយច្បាប់ ប៉ុន្តែការបកស្រាយនេះមិនត្រូវបកស្រាយឱ្យហួសពីវិសាលភាព និងគោលបំណងនៃមាត្រា ៤៨៦ នេះទេ។ ការបកស្រាយពីបុគ្គលដែលមានផលប្រយោជន៍ត្រឹមត្រូតាមផ្លូវ

ច្បាប់ គឺត្រូវពិចារណាថាបុគ្គលនោះអាចត្រូវបានទទួលស្គាល់ថាជាបុគ្គលដែលមានសិទ្ធិលើកឡើងពីអាជ្ញាយុកាលដែរ ឬទេ?

### ២.២.២. អានុភាពប្រតិសកម្ម

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានអានុភាពប្រតិសកម្មចាប់ពីថ្ងៃចាប់ផ្ដើមគិតអាជ្ញាយុកាល (ពេលដែលអាចអនុវត្តសិទ្ធិលើបំណុលបាន) មានន័យថា បើអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានកន្លងផុត ដូច្នេះសិទ្ធិលើបំណុលត្រូវរំលត់ដោយប្រតិសកម្មចាប់ពីថ្ងៃចាប់ផ្ដើមគិតអាជ្ញាយុកាល និងនាំឱ្យកូនបំណុលរួចផុតពីកាតព្វកិច្ចក្នុងការបង់ការប្រាក់ ឬសំណងការខូចខាតផ្សេងៗ ទៀត ក្នុងអំឡុងពេលចាប់ផ្ដើមគិតអាជ្ញាយុកាល[41]។

ឧទាហរណ៍: ក ខ្ចីប្រាក់ ១០០ ដុល្លារ ពី ខ ហើយកំណត់សងនៅថ្ងៃទិ ០១ ខែ មករា ឆ្នាំ ២០០៦។ រហូតដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១១ ទើប ខ ប្ដឹងទាមទារលុយពី ក។ ករណីនេះដោយអាជ្ញាយុកាលបានកន្លងផុត ៥ ឆ្នាំ ហើយសិទ្ធិលើបំណុលអាចរលត់ដោយការលើកឡើងនូវអាជ្ញាយុកាល។ ពេលសិទ្ធិលើបំណុលរលត់នាំឱ្យ ក មិនចាំបាច់បង់ការប្រាក់ និង សំណងនៃការខូចខាតដល់ ខ ចំពោះអំឡុងពេលពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៦ ដល់ថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១១ ព្រមទាំងប្រាក់ដើមទេ ព្រោះដោយសារអានុភាពប្រតិសកម្មនៃអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលដែលបញ្ញត្តិនៅក្នុងមាត្រា ៤៨៥។

## ២.៣. ករណីនៃការផ្អាក និងការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ទោះបីជាអំឡុងពេល ៥ឆ្នាំបានកន្លងហួសគិតចាប់ពីពេលដែលម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនក៏ដោយ ប្រសិនបើមានមូលហេតុនៃការផ្អាក ឬការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះបានកើតឡើង កូនបំណុលនៅតែមានកាតព្វកិច្ចអនុវត្តចំពោះម្ចាស់បំណុលដដែល។ ខាងក្រោមនេះ គឺជាការបង្ហាញអំពីការផ្អាក និងការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក៏ដូចជាហេតុដែលគ្មានអានុភាពនាំឱ្យផ្អាក ឬបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។

[41] មាត្រា ៤៨៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

## ២.៣.១. ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

### ២.៣.១.១. និយមន័យ

ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺជាការបញ្ឈប់ដំណើរការនៃអាជ្ញាយុកាល ក្នុងករណីដែលមានហេតុកំណត់មួយចំនួនដែលបានកំណត់ដោយច្បាប់ (ហេតុនៃការផ្អាក) ដែលត្រូវបានយល់ឃើញថាមិនគួរឱ្យអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ ដំណើរការបន្តទៀត។ ក្នុងករណីនេះ ការផ្អាកនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល គឺមិនត្រឹមតែផ្អាកដំណើរការនៃអាជ្ញាយុកាលនោះមួយអំឡុងពេលទេ គឺចាត់ទុកថា អំឡុងពេលនៃអាជ្ញាយុកាលដែលមានដំណើរការកន្លងមកនោះ ពុំមានអត្ថន័យតាមផ្លូវច្បាប់។ ដូច្នេះហើយ ពេលដែលហេតុនៃការផ្អាកនោះរលត់ទៅ អំឡុងពេលនៃអាជ្ញាយុកាលនឹងចាប់ផ្ដើមគិតសាជាថ្មីម្ដងទៀត។

### ២.៣.១.២. មូលហេតុដែលនាំឱ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ការផ្អាកអាជ្ញាយុកាលរំលត់សិទ្ធិលើបំណុលត្រូវមានមូលហេតុដែលបានកំណត់ដោយច្បាប់[42]។ មូលហេតុនៃការផ្អាកទាំងនោះរួមមាន ការទាមទារតាមផ្លូវតុលាការ ការចូលរួមក្នុងនីតិវិធីធនក្ស័យ សកម្មភាពអនុវត្តដោយបង្ខំ សកម្មភាពចាត់ចែងរក្សាការពារ ការទទួលស្គាល់កាតព្វកិច្ចជាដើម។

#### ២.៣.១.២.១. ការទាមទារតាមផ្លូវតុលាការ

ជាគោលការណ៍ ម្ចាស់បំណុលអាចធ្វើការទាមទារតាមផ្លូវតុលាការឱ្យកូនបំណុលអនុវត្តកាតព្វកិច្ច។ ការទាមទារតាមផ្លូវតុលាការនេះធ្វើឡើងតាមរយៈការដាក់ពាក្យបណ្ដឹងទាមទារឱ្យផ្ដល់តាវកាលិក ឬការជ្រើសរើសយកនីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិច[43] ឬតាមរយៈនីតិវិធីដាស់តឿន[44]។ ការទាមទារតាមផ្លូវតុលាការនាំឱ្យមានអានុភាព ផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ចាប់តាំងពីថ្ងៃដែលម្ចាស់បំណុលបានដាក់ពាក្យបណ្ដឹង ឬពាក្យសុំនៅតុលាការ។ ក៏ប៉ុន្តែ ដើម្បីឱ្យការទាមទារតាមផ្លូវតុលាការមានអានុភាពផ្អាកអាជ្ញាយុកាលបាន លុះត្រាតែពាក្យបណ្ដឹង ឬពាក្យសុំនោះត្រឹមត្រូវតាមច្បាប់ ហើយតុលាការយកមកចាត់ការតាមនីតិវិធី ។ ផ្ទុយទៅវិញ ប្រសិនបើពាក្យ

---

[42] មាត្រា ៤៨៩ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[43] ម្ចាស់បំណុលអាចជ្រើសរើសយកនីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិចចំពោះបណ្ដឹងដែលមានគោលបំណងទាមទារសំណងជាទឹកប្រាក់មិនលើសពី ១លានរៀល ដែលជាតម្លៃកម្មវត្ថុនៃបណ្ដឹង។

[44] តុលាការអាចចេញដីកាសម្រេចដាស់តឿន លុះត្រាតែអាចធ្វើការបញ្ជូនដីកានោះនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានតាមវិធីក្រៅពីការបញ្ជូនតាមការផ្សាយជាសាធារណៈ។

បណ្តឹង ឬពាក្យសុំនោះ ត្រូវបានតុលាការលើកចោលនោះវាមិននាំឱ្យមានអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ តែវានាំឱ្យអោយមានអានុភាពនៃការបង្អង់ទៅវិញ ប្រសិនបើពាក្យសុំ ឬពាក្យបណ្តឹងត្រូវបានបញ្ជូនទៅដល់កូនបំណុល។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល នឹងត្រូវរាប់គិតចាប់ផ្តើមសាជាថ្មី នៅពេលដែលនីតិវិធីនៃបណ្តឹងត្រូវបានបញ្ចប់ពោលគឺ ការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា ឬដីកាសម្រេចដាស់តឿន ដែលភ្ជាប់ជាមួយការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។

ឧទាហរណ៍: ម្ចាស់បំណុលបានដាក់ពាក្យបណ្តឹងនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ ពាក្យបណ្តឹងនោះត្រឹមត្រូវតាមច្បាប់ ហើយតុលាការបានចាត់ការលើពាក្យបណ្តឹងនោះ តាមនីតិវិធី ដូច្នេះអាជ្ញាយុកាលត្រូវបានផ្អាកចាប់តាំងពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៦ រហូតដល់ពេលដែលនីតិវិធីនៃបណ្តឹងត្រូវបានបញ្ចប់។

### ២.៣.១.២.២. ការចូលរួមក្នុងនីតិវិធីក្ស័យធន

ក្ស័យធនសំដៅដល់ស្ថានភាពរបស់ពាណិជ្ជករ ឬនីតិបុគ្គលមិនអាចទូទាត់សងបំណុលបាន ហើយត្រូវបានប្រកាសបញ្ជាក់ដោយតុលាការ។ ការចូលរួមរបស់ម្ចាស់បំណុលនៅក្នុងនីតិវិធីធនក្ស័យគឺបង្ហាញឱ្យឃើញថាម្ចាស់បំណុលមានឆន្ទៈក្នុងការអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនដើម្បីទទួលបានផលប្រយោជន៍ដែលខ្លួនមានលើកូនបំណុលធនក្ស័យ។ ចំណែកឯនីតិវិធីធនក្ស័យអាចចាប់ផ្តើមបានទាល់តែមានការបញ្ជាក់ពីតុលាការ[45]។ ការចូលរួមក្នុងនីតិវិធីធនក្ស័យ វាស្ទើរតែមានលក្ខណៈប្រហាក់ប្រហែលនឹងការទាមទារតាមផ្លូវតុលាការដូចជាការដាក់ពាក្យបណ្តឹងដែរ។ ក៏ប៉ុន្តែគ្រាន់តែការចូលរួមក្នុងនីតិវិធីធនក្ស័យជាការទាមទារនូវចំណែកនៃសិទ្ធិលើបំណុលរបស់ខ្លួនពីកូនបំណុលដែលមានស្ថានភាពក្ស័យធន។

### ២.៣.១.២.៣. សកម្មភាពអនុវត្តដោយបង្ខំ

បន្ទាប់ពីនីតិវិធីនៃបណ្តឹងត្រូវបានបញ្ចប់ជាស្ថាពរ ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ខ្លួនម្ចាស់បំណុលត្រូវដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំនៅតុលាការអនុវត្ត ឬអាជ្ញាសាលាដែលមានសមត្ថកិច្ចតាមប្រភេទនៃការអនុវត្តដោយបង្ខំ។ ការដាក់ពាក្យសុំនេះ នាំឱ្យមានអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ចាប់តាំងពីពេលដែលបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ។ ដើម្បីឱ្យអានុភាពនេះកើតឡើង លុះត្រាតែពាក្យសុំនោះ ត្រឹមត្រូវតាមច្បាប់ ហើយត្រូវបាន

---

[45] មាត្រា ១២ នៃច្បាប់ស្តីពីក្ស័យធនឆ្នាំ ២០០៧

តុលាការអនុវត្ត ឬអាជ្ញាសាលា ទទួលយកមកចាត់ការតាមនីតិវិធីច្បាប់ ។ ក៏ប៉ុន្តែ ប្រសិនបើ ពាក្យសុំនោះត្រូវបានលើកចោលដោយមូលហេតុដែលមានកំណត់តាមក្រមនីតិវិធីរដ្ឋប្បវេណី[46] នោះនឹងមិនបង្កើតឱ្យមានអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ។ ម្យ៉ាងវិញទៀត នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ តុលាការអនុវត្តក៏អាចផ្អាកនីតិវិធីនៃការអនុវត្តដោយបង្ខំបានដែរ ហើយការផ្អាកនេះ ក៏អាចអូសបន្លាយអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលតាមរយៈសកម្មភាពនៃការអនុវត្តដោយបង្ខំបានដែរ។

ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសកម្មភាពនៃការអនុវត្តដោយបង្ខំបាត់បង់អានុភាពដោយសារការបញ្ចប់នីតិវិធីនៃការអនុវត្តដោយបង្ខំ ពោលគឺ ការបញ្ចប់នីតិវិធីនៃការចែកចំណែក។ ហើយអំឡុងពេលនៃអាជ្ញាយុកាលនឹងត្រូវរាប់គិតចាប់ ផ្តើមសាជាថ្មីឡើងវិញ ប្រសិនបើកូនបំណុលនៃការអនុវត្តមិនទាន់បានអនុវត្តកាតព្វកិច្ចរបស់ខ្លួនឱ្យបានពេញលេញ ម្ចាស់បំណុលនៅតែអាចធ្វើការទាមទារឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចដែលនៅសល់នោះបាន តាមរយៈសកម្មភាពនៃការអនុវត្តដោយបង្ខំ។ ក៏ប៉ុន្តែ ការទាមទារនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ៥ឆ្នាំ គិតចាប់ពីពេលដែលការអនុវត្តដោយបង្ខំបានចប់ជាស្ថាពរ។

សកម្មភាពអនុវត្តដោយបង្ខំដែលបានធ្វើឡើងចំពោះបុគ្គលក្រៅពីកូនបំណុល ត្រូវបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល លុះត្រាតែសកម្មភាពនោះត្រូវបានជូនដំណឹងទៅកូនបំណុល[47]។

ឧទាហរណ៍: ក្នុងករណីដែលម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុដែលជាប់ហ៊ីប៉ូតែកដែលបានផ្តល់ដោយអ្នកធានាដោយវត្ថុ ប្រសិនបើបានជូនដំណឹងទៅកូនបំណុល អានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងកើតឡើងចំពោះកូនបំណុល។

### ២.៣.១.២.៤. សកម្មភាពចាត់ចែងរក្សាការពារ

ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយមូលហេតុម្ចាស់បំណុលបានដាក់ពាក្យសុំឱ្យចាត់ចែងរក្សាការពារ ត្រូវមានអានុភាពចាប់តាំងពីពេលដែល ពាក្យសុំនោះត្រូវបានដាក់ទៅតុលាការអនុវត្តដីកាសម្រេចរក្សាការពារ ឬអាជ្ញាសាលា រហូតដល់ពេលដែលអានុភាពនៃការ

[46] មាត្រា ៣៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[47] មាត្រា ៤៩៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ចាត់ចែងរក្សាការពារត្រូវបានបញ្ចប់ ពោលគឺតុលាការអាចចេញដីកាសម្រេចលុបចោលដីកាសម្រេចរក្សាការពារបានគ្រប់ពេលវេលា។ ការចាត់ចែងរក្សាការពារ គឺជាសកម្មភាពដែលមានលក្ខណៈជាការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជាបណ្តោះអាសន្ន។ នៅពេលណាដែលតុលាការបានលុបចោលការចាត់ចែងរក្សាការពារនោះ អំឡុងពេលនៃអាជ្ញាយុកាលត្រូវរាប់គិតចាប់ផ្តើមសាជាថ្មីឡើងវិញ ។ ក៏ប៉ុន្តែប្រសិនបើតុលាការបានបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយឱ្យដាក់ឯកសារដែលបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះ នៅក្នុងអំឡុងពេល ២ សប្តាហ៍ ប្រសិនបើ ម្ចាស់បំណុលមិនបានដាក់ឯកសារបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងក្នុងអំឡុងពេល តុលាការក៏អាចលុបចោល ដីកាសម្រេចរក្សាការពារតាមពាក្យសុំរបស់កូនបំណុលដែរ។ មានន័យថាអំឡុងពេលនៃអាជ្ញាយុកាលត្រូវរាប់គិតចាប់ផ្តើមសាជាថ្មី នៅពេលដែលមានដីកាសម្រេចលុបចោលដីកាសម្រេចការពារ។ ការលុបចោលដីកាសម្រេចរក្សាការពារ មានមូលហេតុ ៣ យ៉ាង៖

1. ម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹង ឬឯកសារបញ្ជាក់ដើម្បីដាក់ពាក្យបណ្តឹងក្នុងអំឡុងពេល ២សប្តាហ៍ ឬពាក្យបណ្តឹងនោះត្រូវបានលើកចោល[48]។
2. ការលុបចោលដីកាសម្រេចរក្សាការពារដោយសារការផ្លាស់ប្តូរនូវសកម្មភាព បើមានការរលត់សិទ្ធិ ឬទំនាក់ទំនងគតិយុត្តិ ដែលត្រូវបានរក្សាការពារ ឬភាពចាំបាច់ក្នុងការរក្សាការពារ ឬការផ្លាស់ប្តូរស្ថានភាពផ្សេងទៀត[49]។
3. ការលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយសារស្ថានភាពពិសេស ប្រសិនបើមានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តុលាការអាចលុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ននោះ ដោយឱ្យដាក់ប្រាតិភោគតាមពាក្យសុំរបស់កូនបំណុល[50]។

សកម្មភាពចាត់ចែងរក្សាការពារដែលបានធ្វើឡើងចំពោះបុគ្គលក្រៅពីកូនបំណុល ត្រូវបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល លុះត្រាតែសកម្មភាពនោះត្រូវបានជូនដំណឹងទៅកូនបំណុល[51]។

---

[48] មាត្រា ៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[49] មាត្រា ៥៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[50] មាត្រា ៥៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[51] មាត្រា ៤៩៣ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

ឧទាហរណ៍: ក្នុងករណី ម្ចាស់បំណុលបានរឹបអូសជាបណ្ដោះអាសន្នចំពោះទ្រព្យសម្បត្តិរបស់អ្នកធានាដោយវត្ថុ (ហ៊ីប៉ូតែក) ប្រសិនបើបានជូនដំណឹងទៅកូនបំណុល អានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនឹងកើតឡើងចំពោះកូនបំណុលដែរ។

**២.៣.១.២.៥. ការទទួលស្គាល់កាតព្វកិច្ច**

ការទទួលស្គាល់កាតព្វកិច្ច គឺជាមូលហេតុមួយក្នុងចំណោមមូលហេតុដទៃទៀតនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ការទទួលស្គាល់កាតព្វកិច្ច គឺជាការទទួលស្គាល់នូវអត្ថិភាពនៃកាតព្វកិច្ចដោយកូនបំណុល ពោលគឺកូនបំណុលយល់ព្រមអនុវត្តកាតព្វកិច្ច។ ក្នុងករណីដែលកូនបំណុលបានទទួលស្គាល់នូវកាតព្វកិច្ចដោយសកម្មភាពរបស់ខ្លួន ចាំបាច់ត្រូវការពារផលប្រយោជន៍របស់ម្ចាស់បំណុលដែលអាចរងចាំ ដោយមិនអនុវត្តសិទ្ធិដោយមានជំនឿទៅលើសកម្មភាពនោះ។ ផ្ទុយទៅវិញ មិនសូវមានការចាំបាច់ការពារផលប្រយោជន៍កូនបំណុលទេ ដូច្នេះហើយនេះគឺជាហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ក៏ប៉ុន្តែ ប្រសិនបើក្រមរដ្ឋប្បវេណីចែងតែពីការទទួលស្គាល់វាមិនមានលក្ខណៈច្បាស់លាស់ទេ ដូច្នេះក្រមរដ្ឋប្បវេណីបានបញ្ញត្តយ៉ាងច្បាស់លាស់អំពីមូលហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលតាមរយៈការទទួលស្គាល់របស់កូនបំណុលដោយធ្វើការសងមួយផ្នែក ឬការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬវិធីផ្សេងទៀតដែលអាចធានាបានថា កូនបំណុលមានឆន្ទៈអនុវត្តកាតព្វកិច្ច[52]។

**ក. ការសងមួយផ្នែក**

ដើម្បីបញ្ជាក់ឱ្យបានច្បាស់ថាកូនបំណុលពិតជាបានយល់ព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនប្រាកដមែននោះ កូនបំណុលអាចធ្វើការសងមួយផ្នែកនៃកាតព្វកិច្ចទាំងមូលទៅតាមលទ្ធភាពជាក់ស្ដែងរបស់ខ្លួន។ ការសងមួយផ្នែកនេះក៏អាចនាំឱ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានដែរ។ ម្យ៉ាងវិញទៀត ប្រសិនបើម្ចាស់បំណុលទទួលការសងមួយផ្នែក ការសងនោះមានអានុភាព ហើយកាតព្វកិច្ចត្រូវកាត់បន្ថយនៅត្រឹមតុល្យាភាពនៃចំនួនសរុប។ ប្រសិនបើ ការសងមួយផ្នែកនេះមានសុពលភាព វាក៏អាចបង្កើតឱ្យមានអានុភាពអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានដែរ។

ឧទាហរណ៍: កូនបំណុលដែលមានកាតព្វកិច្ច ១០០០ ដុល្លារ បានស្នើសុំផ្ដល់ការសង ៦០០ ដុល្លារទៅម្ចាស់បំណុល។ ក្នុងករណីនេះ ប្រសិនបើម្ចាស់បំណុលទទួលយកការសងនោះ នាំឱ្យការ

[52] មាត្រា ៤៨៩ ចំណុច គ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧

សងនោះមានសុពលភាព ហើយអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក៏កើតមានដែរ។

**ខ. ការបង់ការប្រាក់**

ដើម្បីធានាឱ្យបានច្បាស់ថា កូនបំណុលពិតជាមានឆន្ទៈអនុវត្តកាតព្វកិច្ច កូនបំណុលអាចធ្វើការបង់ការប្រាក់មុនប្រាក់ដើមក៏បាន។ ការបង់ការប្រាក់នេះ ប្រសិនបើម្ចាស់បំណុលបានទទួលត្រូវចាត់ទុកថាម្ចាស់បំណុលបានអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួន ហើយអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានផ្អាក។ ពីព្រោះថាការបង់ការប្រាក់នេះ វាបង្ហាញឱ្យឃើញច្បាស់ថា កូនបំណុលបានទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួន ហើយវាគ្មានន័យអ្វីដែលត្រូវឱ្យអំឡុងពេលនៃអាជ្ញាយុកាលមានដំណើរការឡើយ។

ឧទាហរណ៍: នៅក្នុងកិច្ចសន្យាខ្ចីបរិភោគ កូនបំណុលបានធ្វើការបង់ការប្រាក់ជារៀងរាល់ខែ នោះអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានផ្អាក ហើយអានុភាពនៃការផ្អាកនោះ ត្រូវបញ្ចប់នៅពេលដែលកូនបំណុលលែងបង់ការប្រាក់ទៅឱ្យម្ចាស់បំណុល។

**គ. ការដាក់ប្រាតិភោគ**

ដើម្បីធានាថាកូនបំណុលពិតជាទទួលស្គាល់កាតព្វកិច្ចរបស់ខ្លួនពិតប្រាកដមែន កូនបំណុលត្រូវធ្វើការដាក់ប្រាតិភោគ ដើម្បីឱ្យម្ចាស់បំណុលមានជំនឿទុកចិត្តលើកូនបំណុល។ ដូច្នេះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានផ្អាក ដោយហេតុថាម្ចាស់បំណុលមិនអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួន ក៏ព្រោះតែម្ចាស់បំណុលមានជំនឿទុកចិត្តចំពោះការដាក់ប្រាតិភោគរបស់កូនបំណុល។ ក្នុងករណីនេះ ម្ចាស់បំណុលនៅតែអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបានដដែល ទោះបីជា កូនបំណុលចង់គេចវេសមិនអនុវត្តកាតព្វកិច្ចក៏ដោយ។

ឧទាហរណ៍: កូនបំណុលបានធ្វើការបង្កើតសិទ្ធិលើការបញ្ចាំនូវទ្រព្យសម្បត្តិរបស់ខ្លួនចំពោះម្ចាស់បំណុល។

**២.៣.១.៣. អានុភាព**

ក្នុងមាត្រា ៤៩០ នៃក្រមរដ្ឋប្បវេណី មានចែងពីអានុភាពនៃការផ្អាកពីករណីគឺ: បើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលកើតឡើងចំពោះកូនបំណុលនោះ ការផ្អាកនេះក៏កើតមានឡើងចំពោះអ្នកដទៃដែរ។

ប៉ុន្តែ បើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល កើតឡើងចំពោះភាគីដទៃទៀត ក្រៅពីកូនបំណុល នោះការផ្អាកមានអានុភាពតែរវាងម្ចាស់បំណុល និងភាគីនោះតែប៉ុណ្ណោះ លើកលែងតែករណីមានចែងក្នុងមាត្រា ៤៩៣ នៃក្រមរដ្ឋប្បវេណី ដែលមានន័យថា ទោះបីជាសកម្មភាពអនុវត្តដោយបង្ខំ ឬសកម្មភាពចាត់ចែងរក្សាការពារត្រូវបានធ្វើឡើងចំពោះភាគីផ្សេងទៀត (ក្រៅពីកូនបំណុល) ក៏ដោយ ក៏សកម្មភាពនោះ បង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ប្រសិនបើសកម្មភាពនោះ ត្រូវបានជូនដំណឹងទៅកូនបំណុល។

ឧទាហរណ៍: លោក ក បានខ្ចីប្រាក់ពី លោក ខ។ លោក គ បានយកដីរបស់គាត់ទៅដាក់ប្រាតិភោគ (ហ៊ីប៉ូតែក) ដើម្បីធានាកាតព្វកិច្ចរបស់ ក។

នៅក្នុងករណីនេះ ប្រសិនបើ លោក ខ ដាក់ពាក្យប្តឹង លោក ក ដើម្បីទាមទារសិទ្ធិលើបំណុលដែលកើតឡើងពីកិច្ចសន្យាខ្ចីបរិភោគ នោះវានឹងផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលចំពោះបុគ្គលគ្រប់រូប។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើ លោក ខ អនុវត្តហ៊ីប៉ូតែករបស់គាត់ វានឹងបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ចំពោះតែ លោក គ ប៉ុណ្ណោះ ប្រសិនបើមិនបានជូនដំណឹងទៅ លោក ក ទេ (មាត្រា ៤៩៣)។

### ២.៣.២. ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

#### ២.៣.២.១. និយមន័យ

ការបង្អង់ គឺជាការបញ្ឈប់នៃដំណើរការនៃអាជ្ញាយុកាលតែក្នុងអំឡុងពេលដែលត្រូវបង្អង់នោះប៉ុណ្ណោះ ដូច្នេះ ខុសពីការផ្អាក អំឡុងពេលដែលបានកន្លងផុតទៅ មិនមែនគ្មានន័យទេ។ ការបង្អង់នូវអាជ្ញាយុកាល គឺគ្រាន់តែជាការធ្វើកុំឱ្យអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានសម្រេចប៉ុណ្ណោះ មានន័យថា គ្រាន់តែជាការបញ្ឈប់នូវដំណើរការនៃអាជ្ញាយុកាល នៅដំណាក់កាលកចុងក្រោយដែលជាពេលបញ្ចប់នៃអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។

#### ២.៣.២.២. មូលហេតុនៃការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

មូលហេតុនៃការបង្អង់អាជ្ញាយុកាលនៃរំលត់សិទ្ធិលើបំណុលខុសគ្នាពីមូលហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ហើយអានុភាពនៃការបង្អង់ក៏ខុសគ្នាដែរ។ មូលហេតុនៃការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានដូចខាងក្រោម៖

### ២.៣.២.២.១. ការលើកពាក្យបណ្ដឹង

ទោះបីជាការទាមទារតាមផ្លូវតុលាការមិនបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាល ដោយសារលើកចោលបណ្ដឹង ឬការដកពាក្យបណ្ដឹង ក៏ត្រូវចាត់ទុកថា អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ខែ បន្ទាប់ពីការលើកចោលបណ្ដឹង ឬការដកពាក្យបណ្ដឹងឡើយ[53]។ មានន័យថា ប្រសិនបើ អំឡុងពេលដើម្បីសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលនៅសល់ ត្រូវរាប់បន្តទៀតបន្ទាប់ពីហួសអំឡុងពេល ៦ខែ។

### ២.៣.២.២.២. អនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ

ក្នុងករណីដែលម្ចាស់បំណុលជាអនីតិជន ឬជននៅក្រោមអាណាព្យាបាលទូទៅ ហើយគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ នៅពេលណាមួយក្នុងអំឡុងពេល ៦ខែ មុនពេលផុតអំឡុងនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ នឹងត្រូវបង្អង់ចំពោះកូនបំណុលក្នុងអំឡុងពេល ៦ខែ បន្ទាប់ពីម្ចាស់បំណុលក្លាយជាសមត្ថជន ឬពេលដែលមានអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានជ្រើសតាំង[54]។ ការចែងដូចនេះ គឺដើម្បីទុកលទ្ធភាពឱ្យម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបាន ព្រោះថាក្នុងអំឡុងពេល ៦ខែមុខសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះ ម្ចាស់បំណុល គឺជាអសមត្ថជនដែលមិនអាចអនុវត្តសិទ្ធិ ហើយក៏គ្មានអ្នកដែលអាចអនុវត្តសិទ្ធិជំនួសតាមផ្លូវច្បាប់បានឡើយ។ ចំណែកឯ ការចែងទុកអំឡុងពេល ៦ខែ បន្ទាប់ពីពេលដែលម្ចាស់បំណុលក្លាយជាសមត្ថជន ឬអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានជ្រើសតាំង គឺទុកអំឡុងពេលអាចឱ្យម្ចាស់បំណុល ឬអ្នកតំណាងដែលច្បាប់បានកំណត់នោះអាចត្រៀមលក្ខណៈសម្បត្តិដើម្បីអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបាន។

### ២.៣.២.២.៣. សិទ្ធិលើបំណុលប្ដីប្រពន្ធ

ក្នុងករណីដែលសហព័ទ្ធម្ខាងមានសិទ្ធិលើបំណុល លើសហព័ទ្ធម្ខាងទៀតក្នុងអំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍មិនទាន់បានរលត់ ទោះបីជាអំឡុងពេលនៃអាជ្ញាយុកាលនោះ មានអំឡុងពេលលើសពី ៥ឆ្នាំ ក៏ដោយ ក៏អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចចំពោះសហព័ទ្ធម្ខាងដែលជាកូនបំណុលឡើយ [55] ។ អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបាន

---

[53] មាត្រា ៤៩៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[54] មាត្រា ៤៩៦ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[55] មាត្រា ៤៩៧ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

បង្អង់ក្នុងអំឡុងពេល ៦ខែក្រោយពីការរលាយអាពាហ៍ពិពាហ៍ ហើយការរលាយអាពាហ៍ពិពាហ៍រួមបញ្ចូលទាំងការរលាយដោយការលែងលះ ដោយមរណភាពរបស់សហព័ទ្ធម្ខាង ដោយការប្រកាសអំពីការបាត់ខ្លួន និងការលុបចោលអាពាហ៍ពិពាហ៍។ ការចែងយ៉ាងដូច្នេះ គឺដើម្បីបញ្ចៀសនៅការលែងលះគ្នាដោយសារតែសហព័ទ្ធម្ខាងបានប្ដឹងទាមទារតាមផ្លូវតុលាការឱ្យសហព័ទ្ធម្ខាងទៀតអនុវត្តកាតព្វកិច្ច។ ដូច្នេះទើបក្រមរដ្ឋប្បវេណីបញ្ញត្តបង្អង់ការសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលអំឡុងពេល ៦ខែក្រោយពីការរលាយអាពាហ៍ពិពាហ៍។ ប៉ុន្តែ ប្រសិនបើ អំឡុងពេលដើម្បីសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនៅសល់ អំឡុងពេលនោះត្រូវរាប់បន្តទៀតក្រោយអំឡុងពេលបង្អង់ ៦ខែបានកន្លងផុត។

### ២.៣.២.២.៤. មហន្តរាយ

ក្នុងករណីដែលអ្នកមានសិទ្ធិមិនអាចធ្វើសកម្មភាពផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិដូចជា រញ្ជួយដី ខ្យល់ព្យុះ ទឹកជំនន់ ឬប្រធានសក្តិជាដើម។ នៅពេលណាមួយក្នុងអំឡុងពេល ៦ខែមុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះមិនត្រូវបានសម្រេចក្នុងអំឡុងពេល ៦ខែបន្ទាប់ពីហេតុនោះបានកន្លងផុតឡើយ។ ការចែងដូច្នេះដោយសារតែអំឡុងពេល ៦ខែបន្ទាប់ពីហេតុនោះបានបញ្ចប់ ហាក់បីដូចជាសមរម្យសម្រាប់ឱ្យអ្នកដែលមានសិទ្ធិមានពេលវេលាគ្រប់គ្រាន់ដើម្បីធ្វើសកម្មភាពផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ប្រសិនបើមិនមានការចែងបង្អង់អំឡុងពេល ៦ខែនេះទេ ហាក់បីដូចជាអយុត្តិធម៌ចំពោះអ្នកដែលមានសិទ្ធិលើបំណុលដែលខ្លួនមិនបានធ្វើសកម្មភាពផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលមានមែនជាកំហុសរបស់ខ្លួនឡើយ។ម្យ៉ាងទៀត ដោយហេតុថាគ្រោះមហន្តរាយធម្មជាតិ ឬប្រធានសក្តិបានកើតឡើងក្នុងអំឡុងពេលមួយដែលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលហៀបនឹងបានសម្រេចទៅហើយ។

### ២.៣.២.២.៥. ការដាស់តឿន

ការដាស់តឿនត្រូវបានបែងចែកជាពីរ គឺការដាស់តឿនក្រៅផ្លូវតុលាការ និងការដាស់តឿនតាមផ្លូវតុលាការ។ ក្នុងករណីដែលអ្នកមានសិទ្ធិបានធ្វើការដាស់តឿនក្រៅផ្លូវតុលាការនៅពេលណាមួយក្នុងអំឡុងពេល ៦ខែមុនផុតអំឡុងពេលនៃការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចចំពោះកូនបំណុល ក្នុងអំឡុងពេល ៦

ខែបន្ទាប់ពីការដាស់តឿនឡើយ។ ក៏ប៉ុន្តែការដាស់តឿននេះមានអានុភាពបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានតែម្តងប៉ុណ្ណោះ។

ម្យ៉ាងវិញទៀត ប្រសិនបើការទាមទារតាមផ្លូវតុលាការមិនមានអានុភាពនាំឱ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ដោយហេតុថាពាក្យបណ្តឹងនោះមិនត្រឹមត្រូវតាមច្បាប់កំណត់ ឬផ្ទុយច្បាប់[56] ហើយទោះបីជាតុលាការបង្គាប់ឱ្យកែតម្រូវយ៉ាងណាដក៏ដោយ ក៏ដើមចោទ មិនធ្វើការកែតម្រូវនាំឱ្យតុលាការលើកបណ្តឹងចោល ឬម្យ៉ាងទៀត បើដើមចោទបានដកពាក្យបណ្តឹងក៏ត្រូវចាត់ទុកថាម្ចាស់បំណុលបានដាស់តឿនចាប់ពីពេលដែលពាក្យបណ្តឹងត្រូវបានបញ្ជូនទៅភាគីម្ខាងទៀត រហូតដល់ពេលបណ្តឹងត្រូវបានលើកចោល ឬត្រូវបានដក។ ក្នុងករណីនេះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចចំពោះកូនបំណុលក្នុងអំឡុងពេល ៦ខែបន្ទាប់ពីលើកពាក្យបណ្តឹង ឬការដកពាក្យបណ្តឹងឡើយ។

មួយវិញទៀត ប្រសិនបើចុងចម្លើយបានអះអាងពីសិទ្ធិរបស់ខ្លួនក៏ត្រូវចាត់ទុកថាចុងចម្លើយបានដាស់តឿននៅក្នុងពេលដែលបណ្តឹងនោះកំពុងចាត់ការចាប់ពីពេលដែល ចុងចម្លើយបានអះអាងសិទ្ធិរបស់ខ្លួន។ ក្នុងករណីនេះអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមិនត្រូវបានសម្រេចចំពោះដើមចោទក្នុងអំឡុងពេល ៦ខែ បន្ទាប់ពីសាលក្រម ឬសាលដីកានៃបណ្តឹងនោះបានចូលជាស្ថាពរ។

**២.៣.២.៣. អានុភាពនៃការបង្អង់**

ការបង្អង់មានអានុភាពកាត់ផ្តាច់អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្នុងអំឡុងពេលណាមួយតែប៉ុណ្ណោះ ហើយនៅពេលមូលហេតុនៃការបង្អង់ត្រូវបានបញ្ចប់ អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវបានរាប់បន្ត បន្ទាប់ពីអំឡុងពេល ៦ខែនៃការរំលត់ហេតុនៃការបង្អង់អាជ្ញាយុកាលនៃការសម្រេចសិទ្ធិលើបំណុល។

[56] មាត្រា ៧៥ និងមាត្រា ៨១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

## ២.៣.៣. មូលហេតុដែលគ្មានអានុភាពនាំឱ្យផ្អាក ឬបង្អង់

ទោះបីជាមានមូលហេតុមួយចំនួនបានកើតឡើងនៅក្នុងអំឡុងពេល ៥ឆ្នាំគិតចាប់ពីពេលដែលម្ចាស់បំណុលអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនក៏ដោយ ក៏ហេតុនោះមិននាំឱ្យមានអានុភាពនៃការផ្អាក ឬការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលឡើយ។ ហេតុទាំងនោះរួមមានការលើកចោលពាក្យបណ្តឹង ឬការដកពាក្យបណ្តឹង ការលុបចោលការអនុវត្តដោយបង្ខំ ការលុបចោលការចាត់ចែងរក្សាការពារ។

### ២.៣.៣.១. ការលើកចោលពាក្យបណ្តឹង ឬដកពាក្យបណ្តឹងមុនការបញ្ជូនទៅចុងចម្លើយ

ប្រសិនបើដើមចោទដែលជាម្ចាស់បំណុលបានដកពាក្យបណ្តឹងមុនពេលដែលតុលាការបញ្ជូនពាក្យបណ្តឹងនោះទៅឱ្យចុងចម្លើយត្រូវចាត់ទុកថាសកម្មភាពដែលម្ចាស់បំណុលបានធ្វើនេះមិនមានអានុភាពនាំឱ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ ពោលគឺត្រូវចាត់ទុកថាសកម្មភាពនេះមិនកើតឡើងឡើយ។ ម្យ៉ាងវិញទៀត ប្រសិនបើពាក្យបណ្តឹងរបស់ដើមចោទមានលក្ខណៈផ្ទុយនឹងទម្រង់ដែលបានកំណត់នៅក្នុងមាត្រា ៧៥ ហើយតុលាការបានបង្គាប់ឱ្យធ្វើការកែតម្រូវក៏ដោយ ក៏ដើមចោទនៅតែមិនធ្វើការកែតម្រូវ ដែលនាំឱ្យតុលាការចេញដីកាសម្រេចលើកបណ្តឹងចោល ដោយមិនទាន់បញ្ជូនបណ្តឹងនោះទៅចុងចម្លើយ ឬ ពាក្យបណ្តឹងនោះមានលក្ខណៈផ្ទុយច្បាប់ និងមិនអាចកែតម្រូវបានដែលនាំឱ្យតុលាការចេញសាលក្រមលើកបណ្តឹងចោលដោយមិនឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ព្រមទាំងមិនបានធ្វើការបញ្ជូនទៅចុងចម្លើយឡើយ។ ការដកពាក្យបណ្តឹង ឬការលើកចោលពាក្យបណ្តឹងដែលមិនទាន់បានបញ្ជូនទៅចុងចម្លើយគ្មានអានុភាពនាំឱ្យមានការផ្អាក ឬការបង្អង់អ្វីឡើយ ពោលគឺមិនត្រូវចាត់ទុកថាជាការដាស់តឿនឡើយ។

### ២.៣.៣.២. ការលើកចោលការអនុវត្តដោយបង្ខំ

ក្នុងករណីដែលតុលាការអនុវត្ត ឬអាជ្ញាសាលាលុបចោលការចាត់ចែងការអនុវត្តដោយបង្ខំដែលបានធ្វើរួចហើយ ដោយខ្វះលក្ខខណ្ឌតាមផ្លូវច្បាប់ ឬតាមពាក្យសុំរបស់ភាគី ត្រូវចាត់ទុកថាសកម្មភាពអនុវត្តដោយបង្ខំមិនបានកើតឡើងឡើយ ហើយសកម្មភាពអនុវត្តដោយបង្ខំដែលបានធ្វើកន្លងមកគ្មានអានុភាពនាំឱ្យផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល[57]។ តុលាការអនុវត្ត ឬ

[57] មាត្រា ៤៩២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

អាជ្ញាសាលាអាចលុបចោលការចាត់ចែងការអនុវត្តក្នុងករណីដែលមានឯកសារដែលបានកំណត់ដូចខាងក្រោមត្រូវបានដាក់៖

- ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថាលុបចោលលិខិតអនុវត្ត។
- ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថាមិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ។
- អនុសារសាលក្រម ឬអនុសារសាលដីកាស្ថាពរដែលប្រកាសថាការផ្សះផ្សា ឬការទទួលស្គាល់ដែលទាក់ទងនឹងលិខិតអនុវត្តគ្មានអានុភាព។
- ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ឬឯកសារផ្សេងទៀតដែលក្រឡាបញ្ជីបានធ្វើ ដែលបញ្ជាក់ថាលិខិតអនុវត្តដែលបានកំណត់ចាប់ពីចំណុច ខ រហូតដល់ចំណុច ង កថាខណ្ឌទី ២ នៃមាត្រា ៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី បាត់បង់អានុភាពដោយសារការដកពាក្យបណ្តឹង ឬមូលហេតុផ្សេងទៀត។
- ឯកសារចម្លងយថាភូតនៃកំណត់ហេតុអំពីការផ្សះផ្សាតាមនីតិវិធីនៃការសម្រេចសេចក្តីដែលកំណត់ថាមិនអនុវត្តដោយបង្ខំ ឬដកពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះវិញ។
- ឯកសារដែលបញ្ជាក់អំពីការដាក់ប្រាតិភោគ ដើម្បីឱ្យរួចផុតពីការអនុវត្តដោយបង្ខំ។
- ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ និងលុបចោលការចាត់ចែងការអនុវត្ត[58]។

### ២.៣.៣.៣. ការលើកចោលការចាត់ចែងរក្សាការពារ

ក្នុងករណីដែលតុលាការលុបចោលការចាត់ចែងរក្សាការពារ តាមពាក្យសុំរបស់ភាគី ឬដោយការខ្វះលក្ខខណ្ឌតាមផ្លូវច្បាប់ ការផ្អាកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដោយសកម្មភាពនេះត្រូវចាត់ទុកថាមិនបានកើតឡើងឡើយ [59] ។ មានន័យថាសកម្មភាពចាត់ចែងរក្សាការពារដែលបានលុបចោលនេះមិនមានអានុភាពនាំឱ្យមានការផ្អាកអាជ្ញាយុកាល នៃការរំលត់សិទ្ធិលើបំណុលឡើយ។ តុលាការអាចលុបចោលការចាត់ចែងរក្សាការពារក្នុងករណីដូចខាងក្រោម៖

- ម្ចាស់បំណុលមិនបានដាក់ពាក្យបណ្តឹង និងឯកសារបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងក្នុងអំឡុងពេលដែលតុលាការបង្គាប់ឱ្យដាក់[60]។
- បើមានការរំលត់សិទ្ធិ ឬទំនាក់ទំនងដែលបានរក្សាការពារ ឬភាពចាំបាច់ក្នុងការរក្សាការពារ ឬការផ្លាស់ប្តូរស្ថានភាពដទៃទៀត[61]។

[58] មាត្រា ៣៧០ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[59] មាត្រា៤៩២ នៃក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

[60] មាត្រា ៥៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

- ប្រសិនបើមានការបារម្ភថាការខូចខាតដែលមិនអាចសងបាននឹងកើតឡើងដោយដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬស្ថានភាពពិសេសផ្សេងទៀត[62]។

[61] មាត្រា ៥៥៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

[62] មាត្រា ៥៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

# សេចក្តីសន្និដ្ឋាន

ក្រោយពីធ្វើការសិក្សាស្រាវជ្រាវនៅលើប្រធានបទស្តីអំពី អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្នុងកិច្ចសន្យា យើងឃើញថាបទដ្ឋានដែលកំណត់អំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមាននៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ ក្រឹត្យច្បាប់លេខ ៣៨ រហូតមកដល់ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ អត្ថបទច្បាប់មុនៗមិនបានចែងលម្អិតអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ ដូចជាការផ្អាក និងការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ក៏ប៉ុន្តែក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានចែងយ៉ាងច្បាស់លាស់អំពីលក្ខខណ្ឌនៃការផ្អាក និងការបង្អង់អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។ ដូច្នេះ បញ្ហាចោទត្រង់ថាប្រសិនបើសិទ្ធិលើបំណុលមួយត្រូវបានបង្កើតឡើងនៅការបរិច្ឆេទដែលក្រឹត្យច្បាប់លេខ ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាត្រូវបានកំពុងអនុវត្ត ហើយនៅតែបន្តអត្ថិភាពរហូតដល់ការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧។ តើគួរយកបញ្ញត្តិស្តីពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមកអនុវត្តក្នុងក្រឹត្យច្បាប់លេខ ៣៨ ឬក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មកអនុវត្ត?

ទាក់ទងនឹងបញ្ហានេះ សូម្បីតែក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក៏មិនបានចែងឱ្យបានច្បាស់លាស់ដែរថាតើគួរជ្រើសយកបញ្ញត្តិនៅក្នុងច្បាប់ណាមួយមកអនុវត្ត។ ចំពោះការយកបញ្ញត្តិច្បាប់ណាមួយមកអនុវត្តប្រាកដជាមានភាពខុសប្លែកគ្នាហើយ ដូចជា ក្រឹត្យច្បាប់លេខ ៣៨ អនុញ្ញាតឱ្យតុលាការលើកអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជំនួសកូនបំណុល ចំណែកឯក្រមរដ្ឋប្បវេណីវិញ មិនអនុញ្ញាតឱ្យតុលាការលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលជំនួសកូនបំណុលទេ។

ដើម្បីដោះស្រាយបញ្ហាដែលកើតមានឡើងនេះ ទើបច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីបានកំណត់ទាក់ទងនឹងការជ្រើសរើសយកបញ្ញត្តិនៅក្នុងច្បាប់ណាមួយមកអនុវត្ត។

ចំពោះការជ្រើសរើសច្បាប់ណាមួយមកអនុវត្តត្រូវបានចែងចេញជាបីលក្ខខណ្ឌ៖

- បញ្ញត្តិស្តីអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្នុងក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តចំពោះសិទ្ធិលើបំណុលដែលមិនទាន់រំលត់ដល់អាជ្ញាយុកាលមុនកាលបរិច្ឆេទនៃការអនុវត្ត។
- ប្រសិនបើអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលបានចាប់ផ្តើមមុនកាលបរិច្ឆេទនៃការអនុវត្តវែងជាងអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី សិទ្ធិលើបំណុលនោះមិនត្រូវផុតអាជ្ញាយុកាលនៃការរំលត់សិទ្ធិ រហូតដល់ពេលផុតអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិដែលបានកំណត់ដោយច្បាប់ ឬបទដ្ឋានគតិយុត្តិកន្លងមក។ ប៉ុន្តែ ក្នុងករណី

ដែលអំឡុងពេលអាជ្ញាយុកាលដែលនៅសល់នោះវែងជាងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលកំណត់នៅក្នុងរដ្ឋប្បវេណី ដោយគណនាចាប់ពីកាលបរិច្ឆេទនៃការអនុវត្ត នោះបញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តដោយគណនាចាប់ពីកាលបរិច្ឆេទនៃការអនុវត្តនោះតទៅ។

- ចំពោះសិទ្ធិដែលគ្មានកំណត់អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិ បញ្ញត្តិស្តីអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលក្នុងក្រមរដ្ឋប្បវេណី ត្រូវយកអនុវត្តដោយគណនាពីកាលបរិច្ឆេទនៃការអនុវត្ត។

ប៉ុន្តែ កន្លងមកនេះប្រជាពលរដ្ឋមិនសូវបានយល់ដឹងទាក់ទងនឹងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ។

តើបញ្ហានេះត្រូវដោះស្រាយយ៉ាងដូចម្តេច?

# អនុសាសន៍

ឆ្លងតាមការបកស្រាយយ៉ាងក្បោះក្បាយរួចមកយើងឃើញថាទាក់ទងនឹងអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី នៅតែមានចំនោទបញ្ហាកើតឡើងបើទោះបីជាមានច្បាប់កំណត់ជាក់លាក់មួយចំនួនក៏ដោយបញ្ហាទាំងនោះតម្រូវឱ្យមានយន្តការដោះស្រាយដូចខាងក្រោមៈ

- រដ្ឋត្រូវមានយន្តឱ្យបានជាក់លាក់បន្ថែមទៀតទាក់ទងនឹងការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋបានយល់ដឹងស៊ីជម្រៅអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ជៀសវាងការភាន់ច្រឡំថាខ្លួននៅតែមានសិទ្ធិលើបំណុរហូត។ រដ្ឋអាចបង្កើតឱ្យមានកម្មវិធីតាមទូរទស្សន៍ វិទ្យុ ឬប្រព័ន្ធផ្សព្វផ្សាយផ្សេងទៀតដើម្បីបកស្រាយច្បាប់ទាក់ទងនឹងប្រធានបទ(អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល) ហើយបើកឱកាសឱ្យសាធារណជនបានចូលរួមដោយសេរី។
- ម្ចាស់បំណុលក៏ត្រូវយកចិត្តទុកដាក់តាមដានការអនុវត្តសិទ្ធិរបស់ខ្លួន កុំបណ្តែតបណ្តោយឱ្យពេលវេលាកន្លងហួសអាជ្ញាយុកាលដែលច្បាប់បានកំណត់។ ម្យ៉ាងទៀតម្ចាស់បំណុលក៏ត្រូវស្វះស្វែងរកអ្នកច្បាប់ដើម្បីពិគ្រោះយោបល់តាមដែលអាចធ្វើទៅបាន ជៀសវាងការបាត់បង់សិទ្ធិរបស់ខ្លួនដោយមិនដឹងខ្លួន។ ជាពិសេសនៅពេលមានវិវាទទាក់ទងនឹងសិទ្ធិលើបំណុលនៅដំណាក់កាលនីតិវិធីតុលាការគួរតែមានមេធាវីការពារក្តី។ ប្រសិនបើអាចម្ចាស់បំណុលគួរតែមានមេធាវីប្រឹក្សាយោបល់នៅពេលចុះកិច្ចសន្យា ដើម្បីឱ្យប្រាកដថាម្ចាស់បំណុលនឹងបានដឹងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល។
- កូនបំណុលត្រូវតែមានមេធាវីការពារក្តីនៅពេលមានវិវាទនៅតុលាការទាក់ទងនឹងអាជ្ញាយុកាលនៃការរំសិទ្ធិលើបំណុល ព្រោះពេលខ្លះកូនបំណុលមិនបានដឹងអំពីអំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេ។ ម្យ៉ាងទៀត ប្រសិនបើកូនបំណូលមិនបានលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទេតុលាការមិនអាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានទេ ហើយកូនបំណុលនឹងបាត់បង់ផលប្រយោជន៍ ប៉ុន្តែប្រសិនបើកូនបំណុលមានមេធាវីការពារវិញគឺគាត់អាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបាន។
- ម្យ៉ាងវិញទៀតក្រមរដ្ឋប្បវេណីគួរតែប្រកាន់យកគោលការណ៍ថៅក្រមសកម្ម បានន័យថាតុលាការអាចលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបាន ពីព្រោះថាប្រជាពលរដ្ឋខ្មែរភាគច្រើនសុទ្ធតែមិនសូវបានយល់ដឹងពីបញ្ហានេះទេ។ ប្រសិបើពួកគាត់បានដឹងហើយ នៅតែមិនលើកឡើងពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទៀត នោះទើបនិយាយបានថាគាត់មានសិទ្ធិហើយ មិនប្រើប្រាស់សិទ្ធិរបស់ខ្លួន ប៉ុន្តែប្រសិនបើគាត់មិនបានដឹងពីសិទ្ធិរបស់ខ្លួនទេ វាជារឿង

ដែលគួរឱ្យសោកស្តាយដែលសិទ្ធិរបស់ខ្លួនត្រូវបានបាត់បង់។ លើសពីនេះទៅទៀត ច្បាប់គួរតែត្រូវឱ្យមានមេធាវីនៅពេលដែលតុលាការសង្កេតឃើញថាសិទ្ធិលើបំណុលបានហួសអាជ្ញាយុកាល ឬរដ្ឋផ្តល់មេធាវីឱ្យគូភាគីនៃវិវាទប្រសិនបើគាត់គ្មានលទ្ធភាពគ្រប់គ្រាន់។

# ឯកសារយោង

# ឯកសារយោង

០១. ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០ បកប្រែដោយលោក អេង សុត ឆ្នាំ ១៩៦៧

០២. ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

០៣. ក្រឹត្យច្បាប់លេខ៣៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ឆ្នាំ១៩៨៨

០៤. សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណី ភាគ ២ ឆ្នាំ២០០៩

០៥. សេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ភាគ ១ ឆ្នាំ២០១២

០៦. សេចក្តីផ្តើមរដ្ឋប្បវេណីឆ្នាំ២០១១

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ក្រមរដ្ឋប្បវេណីឆ្នាំ ១៩២០

មាត្រា ៩២៨ .– បែបយ៉ាង នៃការរំលត់ នូវកាតព្វកិច្ច ដែល បណ្ដាលមកពីម្ចាស់ បំណុល មិន បានប្ដឹងទារ អស់កាល ជាអង្វែង ពេក ហៅថា អាជ្ញាយុកាល ។

មាត្រា៩២៩ .– បើ កូនបំណុល នៅ ក្នុងឃុំ ទីទៃ ពីឃុំ ម្ចាស់ បំណុល ហើយ ម្ចាស់ នេះ មិន បានទារ ក្នុងកំណត់ ៥ឆ្នាំ តាំងដើម អំពីថ្ងៃ ដែលសន្មត់ ជាត្រូវទារ នោះមក, បំណុល ត្រូវ អស់អាជ្ញាកាល ហើយ, បើ កូនបំណុល នៅក្នុងឃុំ ជាមួយ នឹងម្ចាស់បំណុល ហើយ ម្ចាស់ បំណុល មិន បានទារ ក្នុងកំណត់ ៣ ឆ្នាំ តាំងដើម អំពីថ្ងៃ ដែលដល់សន្មត់ ជាត្រូវទារ នោះ មក, បំណុល នោះ ក៏ត្រូវ អស់អាជ្ញាកាល ដែរ ។

មាត្រា ៩៣០ .– បើ កូន បំណុល បាត់ខ្លួន ពីទីលំនៅហើយ ម្ចាស់ បំណុល បានប្ដឹង ឲ្យមេឃុំ ឬ ជំទប់ ពិនិត្យ ពីបាត់ខ្លួន នេះ មាន កំណត់ហេតុ ត្រឹមត្រូវ, អាជ្ញាយុកាល នោះ ត្រូវ ផ្អាកសិន មិនឲ្យអស់ទេ ។

មាត្រា ៩៣១.– បណ្ដឹង របស់ម្ចាស់ បំណុល ដែលបានប្ដឹង ដល់តុលាការ ក៏ត្រូវ ផ្អាក អាជ្ញាយុកាល ដែរ, ។

មាត្រា៩៣២.– រយៈវេលា ត្រូវ គិត ១២ ខែ ក្នុង ១ឆ្នាំ តាម ចន្ទគតិ ពីតិថី មួយ ទៅតិថី មួយ ។ ថ្ងៃទី ១ ត្រូវរាប់ពីថ្ងៃ ដែលដល់ សន្មត ត្រូវទារ ។ រយៈវេលា ដែលត្រូវគ្រប់ កំណត់ នោះ គឺ វេលា ដែល ផុតថ្ងៃ ទីចុង បង្អស់ នៃខែ គំរប់ ១២ នៃឆ្នាំ ទី ៣ ឬ ឆ្នាំ ទី ៥ តាមរឿង

មាត្រា៩៣៣.– កូនបំណុល ឬ អ្នកធានា អាច នឹងលើកយក អាជ្ញាយុកាល នោះ មកតតាំង គ្រប់សភាពនៃក្ដី បាន ទោះបី ក្នុងជាន់ សាលា ឧទ្ធរណ៍ហើយ សាលា នេះ បានពិភាក្សាដល់អង្គសេចក្ដីទៅហើយ ក៏ដោយ

មាត្រា៩៣៤.– តុលាការ មិនអាច លើក អាជ្ញាយុកាល ពីចិត្ត ឯង មក ជាមធ្យោបាយ ជួស សាមីខ្លួន បាន ទេ ។

មាត្រា៩៣៥.– កូនបំណុល នោះ នឹងទារយក ប្រាក់ ឬ តម្លៃ នោះ មកវិញ ពុំបាន ឡើយ ។

## ផ្នែកទី ៥ . អាជ្ញាយុកាលនៃកិច្ចសន្យា

**មាត្រា៧៥ -** លើកលែងតែច្បាប់ចែងផ្សេងពីនេះ កាតព្វកិច្ចទាំងឡាយដែលកើតចេញពីកិច្ចសន្យាត្រូវផុតអាជ្ញាយុកាល កាលបើភាគីដើមបំណុលមិនប្ដឹងទាមទារឱ្យអនុវត្តក្នុងអំឡុង ៥ ឆ្នាំ គិតពីថ្ងៃកំណត់កិច្ចសន្យា ឬបើគ្មានកំណត់ថ្ងៃទេ ត្រូវគិតពីថ្ងៃចុះកិច្ចសន្យា ។

**មាត្រា៧៦ -** អាជ្ញាយុកាលត្រូវបានផ្អាកសិន កាលបើភាគីកូនបំណុលអវត្តមានពីលំនៅស្ថាន ហើយអវត្តមាននេះត្រូវបានរដ្ឋអំណាចមូលដ្ឋានបញ្ជាក់ត្រឹមត្រូវបានច្បាប់ ។

បណ្ដឹងរបស់ភាគីកូនបំណុល ក៏ត្រូវផ្អាកអាជ្ញាយុកាលនៃកិច្ចសន្យាដែរ ។

**មាត្រា៧៧ -** កូនបំណុល ឬអ្នកធានា អាចនឹងលើកយកអាជ្ញាយុកាលមកតវ៉ាបាន ។ បើកូនបំណុល ឬអ្នកធានាមិនបានលើកយកអាជ្ញាយុកាលមកតវ៉ាទេ តុលាការប្រជាជនត្រូវលើកជូសសាមីខ្លួន ។

**មាត្រា៧៨ -** ភាគីកូនបំណុល ឬអ្នកធានាដែលបានបំពេញកាតព្វកិច្ចដែលផុតអាជ្ញាយុកាលរួចទៅហើយ ពុំអាចទាមទារយកចំនួនទឹកប្រាក់ ឬតំលៃនោះមកវិញបានឡើយ ។

# ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧

## ជំពូកទី ៨
## អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

**មាត្រា ៤៨០.–** និយមន័យនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល សំដៅទៅលើការរលត់សិទ្ធិលើបំណុល ដោយផ្អែកលើការណីដែលម្ចាស់បំណុលមិនអនុវត្តសិទ្ធិ ក្នុងអំឡុងពេលដែលត្រូវបានកំណត់ ។

**មាត្រា ៤៨១.–** ពេលចាប់ផ្ដើមគិតអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល ត្រូវគិតចាប់ពីពេលដែលអាចអនុវត្តសិទ្ធិលើបំណុលនោះបាន ។

**មាត្រា ៤៨២.–** អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលទូទៅ

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិផ្សេងក្នុងក្រមនេះ ឬ ច្បាប់ឬបទដ្ឋានគតិយុត្តផ្សេង ។ ដែលមិនមែនជាពាណិជ្ជករ និង ថ្លៃសេវាដែលផលិតករ ឬ ពាណិជ្ជករផ្ដល់ឱ្យអ្នកដែលមិនមែនជាពាណិជ្ជករ អាជ្ញាយុកាលនៃការរំលត់សិទ្ធិនេះ មានអំឡុងពេល ២ (ពីរ) ឆ្នាំ ។

**មាត្រា ៤៨៤.–** អំឡុងពេលអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលចូលជាស្ថាពរ

១-ចំពោះសិទ្ធិលើបំណុលដែលចូលជាស្ថាពរ ដោយសាលក្រម ឬ សាលដីកាស្ថាពរ ឬ ដោយការផ្សះផ្សាតាមផ្លូវតុលាការ ឬ ដោយវិធីផ្សេងដែលមានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរ ទោះបីជាមានបញ្ញត្តិដែលកំណត់អំឡុងពេលនៃអាជ្ញាយុកាលតិចជាង ៥ (ប្រាំ) ឆ្នាំក៏ដោយ ក៏អាជ្ញាយុកាលនៃការរំលត់សិទ្ធិនោះ ត្រូវមានអំឡុងពេល ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីពេលដែលសិទ្ធិលើបំណុលនោះចូលស្ថាពរដែរ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលពេលកំណត់ត្រូវអនុវត្តមិនទាន់ដល់ នៅពេលនៃការចូលជាស្ថាពរ ។

**មាត្រា ៤៨៥.-** អានុភាពប្រតិសកម្មនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលមានអានុភាពប្រតិសកម្ម ចាប់តាំងពីថ្ងៃចាប់ផ្ដើមគិតអាជ្ញាយុកាលនោះ ។

**មាត្រា ៤៨៦.-** ការលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

១-តុលាការមិនអាចសម្រេចសេចក្ដីដោយយកអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបានឡើយ លើកលែងតែភាគីបានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនោះ ។

២-ក្រៅពីកូនបំណុល មានតែកូនបំណុលដោយសាមគ្គីភាព អ្នកធានា អ្នកធានាដោយវត្ថុ និង តតិយជនដែលបានផ្ទេរលទ្ធកម្ម ដែលបានកំណត់នៅក្នុងមាត្រា ៧៦៦ (និយមន័យនៃអ្នកធានាដោយវត្ថុ និង តតិយជនដែលបានផ្ទេរលទ្ធកម្ម) នៃក្រមនេះ និង បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់ ក្នុងការលើកឡើងនូវអាជ្ញាយុកាលទេ ដែលអាចលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលបាន ។

៣-ប្រសិនបើកូនបំណុលលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល តតិយជនក៏នឹងទទួលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនេះដែរ ។ ប្រសិនបើអ្នកដែលមិនមែនជាកូនបំណុល តែមានសិទ្ធិលើកឡើងនូវអាជ្ញាយុកាល បានលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលនេះ អានុភាពនៃការលើកឡើងនេះ កើតឡើងតែរវាងម្ចាស់បំណុល និង អ្នកដែលលើកឡើងនូវអាជ្ញាយុកាលនៃការរំលត់សិទ្ធិតែប៉ុណ្ណោះ ។

**មាត្រា ៤៨៧.-** ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល

ផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មិនអាចបោះបង់ចោលជាមុនបានទេ ។ មានតែផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលដែលបានសម្រេចហើយទេ ទើបអាចបោះបង់ចោលបាន ។

**មាត្រា ៤៨៨.-** វិសាលភាពនៃជនដែលទទួលអានុភាពនៃការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាល នៃការរំលត់សិទ្ធិលើបំណុល

ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុល មានអានុភាពតែរវាងម្ចាស់បំណុល និង អ្នកមានសិទ្ធិលើកឡើងដែលបានបោះបង់ចោលនូវផលប្រយោជន៍នោះតែប៉ុណ្ណោះ ។

**មាត្រា ៤៨៩.–** ហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល

អាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល ត្រូវផ្អាកក្នុងករណីដូចតទៅ :

ក-ការទាមទារតាមផ្លូវតុលាការ ការចូលរួមក្នុងនីតិវិធីពន្ធក្ស័យ ឬ ការអនុវត្តសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែល ។

ខ-សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារ ។

គ-ការទទួលស្គាល់កាតព្វកិច្ច ដោយការសងមួយផ្នែក ការបង់ការប្រាក់ ការដាក់ប្រាតិភោគ ឬ វិធីផ្សេង ។

**មាត្រា ៤៩០.–** វិសាលភាពនៃជនដែលទទួលអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល

ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល កើតឡើងចំពោះកូនបំណុល អ្នកដទៃទៀតមិនអាចបដិសេធនូវអានុភាពនៃការផ្អាកនេះបានទេ ។ ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃការរលត់សិទ្ធិលើបំណុល កើតឡើងចំពោះអ្នកមានសិទ្ធិលើកឡើង ក្រៅពីកូនបំណុល អានុភាពនៃការផ្អាកនេះត្រូវកើតឡើង តែរវាងម្ចាស់បំណុល និង អ្នកមានសិទ្ធិលើកឡើងតែប៉ុណ្ណោះ ។